GGGI

AFD
AGENCE FRANÇAISE
DE DÉVELOPPEMENT



# របាយការណ៍សិក្សាវាយតម្លៃ អំពីការតាមដានគុណភាពខ្យល់ នៅកម្ពុជា

រក្សាសិទ្ធិ © ២០២៤
វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល
អគារ Jeongdong ជាន់ទី១៩ ២១-១៥ Jeongdong-gil
Jung-gu, សេអ៊ូល ០៤៥១៨
សាធារណរដ្ឋកូរ៉េ

វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល មិន៖ (i) ធ្វើការធានាណាមួយ ទាំងការបង្ហាញ ឬបង្កប់ន័យ ឬ (ii) ទទួលបន្ទុកផ្នែកច្បាប់ ឬទំនួលខុសត្រូវចំពោះសុចរិតភាព សុក្រឹតភាព ឬការប្រើប្រាស់របស់ភាគីទីបី ឬលទ្ធផលនៃការប្រើប្រាស់ព័ត៌មានណាមួយដែលមាននៅទីនេះ (iii) មានគោលបំណងប្រើប្រាស់គំរូ/ណែនាំនេះជាជំនួនផ្នែកច្បាប់ ឬជាការជំនួសដំបូន្មានផ្នែកច្បាប់ ឬ (iv) តំណាងឱ្យការប្រើប្រាស់ដោយភាគីទីបីណាមួយ នឹងមិនរំលោភលើសិទ្ធិឯកជនឡើយ។ ការយល់ឃើញនិងទស្សនៈផ្ទាល់ខ្លួនរបស់អ្នកនិពន្ធដែលបានបង្ហាញនៅទីនេះមិនមានភាពចាំបាច់ក្នុងការបញ្ជាក់ ឬឆ្លុះបញ្ចាំងពីភាគីផ្សេងទៀតនៃវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកលនោះទេ។

# មាតិកា


បញ្ជីអក្សរកាត់ v

១. សារតារ ១

១.១ សេចក្តីផ្តើម ១

១.២ គោលបំណង ២

១.៣ វិសាលភាព និងដែនកំណត់នៃការសិក្សា ៣

១.៤ រចនាសម្ព័ន្ធនៃរបាយការណ៍ ៣

២. ការប្រមូលទិន្នន័យ ៤

២.១ ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់ ៤

២.២ នីតិវិធីថែទាំ និងព្យាសកម្ម ៨

២.៣ ទីតាំងអង្កេតគោលដៅ ៩

២.៤ ការគ្រប់គ្រងទិន្នន័យ ១០

២.៥ សមត្ថភាពបច្ចេកទេស ១១

៣. ការវាយតម្លៃស្ថានីយត្រួតពិនិត្យគុណភាពខ្យល់នៅ រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ ១២

៣.១ បទប្បញ្ញត្តិ ១២

៣.២ ការវាយតម្លៃសិនស័រតម្លៃទាប ១៤

៣.៣ ស្ថានភាពនៃស្ថានីយបង្អែក ២០

៣.៤ ចំណាយប្រតិបត្តិការសម្រាប់ស្ថានីយបង្អែក និងសិនស័រ ២២

៣.៥ ការជ្រើសរើសឧបករណ៍សិនស័រតម្លៃទាប ២៤

៣.៦ ស្ថានភាពនៃសមត្ថភាពបច្ចេកទេសនៅកម្ពុជា ២៦

៣.៧ ការវាយតម្លៃទីតាំងសិនស័រ ២៧

៤. អនុសាសន៍ ៣១

# បញ្ជីអក្សរកាត់

| | |
|---|---|
| AFD | Agence Française de Développement (ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ) |
| APIs | Application Program Interfaces (ផ្ទាំងអនុវត្តកម្មវិធី) |
| AQI | Air Quality Index (សន្ទស្សន៍គុណភាពខ្យល់) |
| AQIP | Air Quality Improvement Project (គម្រោងលើកកម្ពស់គុណភាពខ្យល់) |
| DAQNVM | Department of Air Quality, Noise and Vibration Management (នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ រំញ័រ និងសំឡេង) |
| DMS | Data Management System (ប្រព័ន្ធគ្រប់គ្រងទិន្នន័យ) |
| EANET | Acid Deposition Monitoring Network in East Asia (បណ្តាញត្រួតពិនិត្យការបង្កអាស៊ីដតំបន់អាស៊ីខាងកើត) |
| EPA | United States Environmental Protection Agency (ទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិក) |
| GGGI | Global Green Growth Institute (វិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល) |
| IAT | Intake Air Temperature (សីតុណ្ហភាពខ្យល់ស្រូបចូល) |
| MOE | Ministry of Environment (ក្រសួងបរិស្ថាន) |
| MOs | Metal Oxides Sensors (សិនស័រចាប់ឧស្ម័នមានជាតិលោហៈ) |
| OPC | Optical Particle Counter (ឧបករណ៍រាប់សមាសធាតុអុបទិច) |
| PSC | Project Steering Committee (គណៈកម្មាការដឹកនាំគម្រោង) |
| QA | Quality Assurance (ការធានាគុណភាព) |
| QC | Quality Control (ការត្រួតពិនិត្យគុណភាព) |
| SOP | Standard Operating Procedure (នីតិវិធីប្រតិបត្តិស្តង់ដារ) |
| TWG | Technical Working Group (ក្រុមការងារបច្ចេកទេស) |
| USD | United States Dollar (លុយដុល្លារសហរដ្ឋអាមេរិក) |
| VOC | Volatile Organic Compounds (បណ្តុំសមាសធាតុសរីរាង្គងាយបង្កជាហេតុ) |
| WHO | World Health Organization (អង្គការសុខភាពពិភពលោក) |

# ១. សារតារ

## ១.១ សេចក្តីផ្តើម

ការបំពុលខ្យល់ គឺជាបញ្ហាប្រឈមផ្នែកបរិស្ថាននៅទូទាំងសកលលោក ដែលបង្កផលវិបាកយ៉ាងធំធេងចំពោះ សុខភាពសាធារណៈប្រព័ន្ធអេកូឡូស៊ី និងអាកាសធាតុ។ នៅពេលដែលពិភពលោកដែលមានអន្តរទំនាក់ទំនងទៅវិញទៅមកលើផ្នែកឧស្សាហូបនីយកម្ម និងនគរូបនីយកម្មការយល់ដឹង និងចូលរួមការដោះស្រាយការបំពុលខ្យល់ គឺមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។នៅក្នុងដំណើរអភិវឌ្ឍន៍ប្រទេសកម្ពុជា ជួបប្រទះនឹងបញ្ហាប្រឈមថ្មីៗជាច្រើននៅក្នុងការគ្រប់គ្រងគុណភាពខ្យល់ ដែលជាទិដ្ឋភាពដ៏សំខាន់មួយក្នុងការធានាឱ្យបាននូវសុខុមាលភាពរបស់ប្រជាជន។

> «ការបំពុលខ្យល់ គឺជាបញ្ហាប្រឈមផ្នែកបរិស្ថាននៅទូទាំងសកលលោក ដែលបង្កផលវិបាកយ៉ាងធំធេងចំពោះ សុខភាពសាធារណៈប្រព័ន្ធអេកូឡូស៊ី និងអាកាសធាតុ។»

ក្នុងបរិបទសកល ឥទ្ធិពលនៃការបំពុលខ្យល់ បានវាតទីហួសព្រំដែនប្រទេសទៅទៀត ពោលគឺប៉ះពាល់ដល់ សហគមន៍ទូទាំងពិភពលោកផងដែរ។ កំណើនឧស្សាហកម្មរហ័ស ការកើនឡើងនៃការបញ្ចេញឧស្ម័ន ពីយានយន្ត និងចំហេះឥន្ធនៈផូស៊ីលសុទ្ធតែចូលរួមចំណែកក្នុងការបង្កើនកំហាប់សារធាតុបំពុលនៅក្នុងបរិយាកាស។ សារធាតុបំពុលទាំងនេះមិនត្រឹមតែបង្កហានិភ័យចំពោះសុខភាពប៉ុណ្ណោះទេ តែថែមទាំងចូលរួមចំណែកដល់ការប្រែប្រួលអាកាសធាតុទៀតផងដែលចាំបាច់ ត្រូវមានយុទ្ធសាស្ត្រតាមដានត្រួតពិនិត្យគុណភាពខ្យល់ និងយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ប្រកបដោយប្រសិទ្ធភាពជាបន្ទាន់នៅកម្រិតអន្តរជាតិ។

នៅក្នុងព្រំដែនកម្ពុជា ផលវិបាកនៃការបំពុលខ្យល់ បានបង្ហាញយ៉ាងជាក់ច្បាស់ និងទាមទារឱ្យមានការពិនិត្យ ពិច័យដោយយកចិត្តទុកដាក់។ យោងតាមរបាយការណ៍[1] មួយនៅឆ្នាំ២០១៥ រាជធានីភ្នំពេញ មានកំហាប់សារធាតុ បំពុល PM2.5 នៅកម្រិត 13.59 µg/m3 នៅឆ្នាំ២០១៧ ដែលកើនឡើងដល់ 19.26 µg/m3 នៅឆ្នាំ២០១៨។ គួរកត់សម្គាល់ផងដែរ យើងសង្កេតឃើញមានកម្រិតការបំពុលកើនឡើងចាប់ពីខែមករា ដល់ខែមីនាក្នុងអំឡុងពេលរដូវប្រាំង។ សកម្មភាព និងសំណល់ពីលំនៅដ្ឋាន រួមចំណែកយ៉ាងច្រើនចំពោះការកើនឡើងនេះ ដែលមាន 43% និង 27% នៃប្រភព PM2.5 រៀងគ្នា។ ទន្ទឹមនឹងនេះ វិស័យដឹកជញ្ជូនបានក្លាយជាវិស័យរួមចំណែកចម្បងមួយនៃការបញ្ចេញឧស្ម័ននីត្រូសែនឌីអុកស៊ីត ដែលបញ្ចេញឧស្ម័ននេះរហូតដល់ 71.23% នៃការបញ្ចេញឧស្ម័នសរុប។

នៅពេលដែលយើងចុះសិក្សាវាយតម្លៃត្រួតពិនិត្យគុណភាពខ្យល់ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់នៅកម្ពុជាជាការសំខាន់ណាស់ដែលត្រូវយល់ដឹងអំពីប្រភពនិងការវិវត្តន៍នៃការបំពុលខ្យល់ដែលប៉ះពាល់មកលើប្រទេសកម្ពុជា។ ការវាយតម្លៃនេះមានគោលបំណងត្រួតពិនិត្យលម្អិតទៅលើហេដ្ឋារចនាសម្ព័ន្ធត្រួតពិនិត្យគុណភាពខ្យល់វាយតម្លៃប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះនិងស្នើឡើងវិធានការសម្រាប់ការពង្រឹងបន្ថែម។ផ្នែកដ៏សំខាន់នៃការវាយតម្លៃនេះ រួមមានការស្វែងយល់ពីឧបករណ៍ដែលបានដាក់ដំណើរការ ដើម្បីវាស់ស្ទង់ការបំពុលខ្យល់ឱ្យបានត្រឹមត្រូវ។ ឧបករណ៍

---

1 ផែនការខ្យល់ស្អាតកម្ពុជា ឆ្នាំ ២០២១

ទាំងនេះមិនត្រឹមតែត្រូវបានប្រើជាឧបករណ៍សម្រាប់ការប្រមូលទិន្នន័យប៉ុណ្ណោះទេប៉ុន្តែក៏ជាឧបករណ៍សម្រាប់ការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រផ្អែកលើភស្តុតាងដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាវិកលវាលជាលនៃការបំពុលខ្យល់នៅកម្ពុជា និងចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងជាសកលក្នុងការឆ្ពោះទៅរកបរិស្ថានកាន់តែស្អាត និងមានសុខភាពល្អ។

## ១.២ គោលបំណង

របាយការណ៍វាយតម្លៃនេះដើរតួនាទីយ៉ាងសំខាន់នៅក្នុងការពង្រឹងប្រសិទ្ធភាពនៃត្រួតពិនិត្យគុណភាពខ្យល់ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់នៅកម្ពុជា តាមរយៈការលើកឡើងនូវគោលបំណងសំខាន់ៗដូចជា៖

- **របាយការណ៍នេះដើរតួនាទីជាឯកសារគ្រប់ជ្រុងជ្រោយនៃទស្សនៈចម្រុះ ដោយរួមបញ្ចូលនូវទស្សនៈជាច្រើនអំពីស្ថានភាពបច្ចុប្បន្នរបស់ត្រួតពិនិត្យគុណភាពខ្យល់ ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់។** ឯកសារនេះ ដើរតួនាទីជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការសម្រេចចិត្តយ៉ាងគ្រប់ជ្រុងជ្រោយ ដោយផ្តល់ឱ្យភាគីពាក់ព័ន្ធនូវការយល់ដឹងរួមអំពីចំណុចខ្លាំង និងបញ្ហាប្រឈមដែលហេដ្ឋារចនាសម្ព័ន្ធតាមដានត្រួតពិនិត្យបច្ចុប្បន្នជួបប្រទះ។
- **របាយការណ៍នេះ មានគោលបំណងបង្កើតផែនការមូលដ្ឋានគ្រឹះសម្រាប់ អនាគតដោយគូសបញ្ជាក់ពីវិធានការជាយុទ្ធសាស្ត្រដើម្បីពង្រឹងប្រសិទ្ធផល និងមុខងារដំណើរការរបស់ត្រួតពិនិត្យគុណភាពខ្យល់ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់នៅទូទាំងប្រទេស។** តាមរយៈការធ្វើព្យាសកម្មរកចំណុចដែលត្រូវកែលម្អ និងការស្នើឡើងនូវអនុសាសន៍ដែលអាចយកទៅអនុវត្តបានរបាយការណ៍នេះរួមចំណែកដល់ការរៀបចំផែនការដ៏រឹងមាំនិងត្រៀមទុកជាមុនសម្រាប់ការគ្រប់គ្រងគុណភាពខ្យល់នៅកម្ពុជា។
- **របាយការណ៍នេះ បានស្វែងយល់ស៊ីជម្រៅអំពីដំណើរការទាំងមូល នៃការធានាទិន្នន័យពិធីសារនិងវិធីសាស្ត្រត្រួតពិនិត្យដែលមានដើម្បីធានាបាននូវសុក្រឹតភាព និងភាពអាចទុកចិត្តបានទៅលើទិន្នន័យដែលប្រមូលបាន។** ការធ្វើដូច្នេះមិនត្រឹមតែជួយវាយតម្លៃអំពីទិដ្ឋភាពបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយធានាឱ្យបានថាព័ត៌មានដែលទទួលបានពីស្ថានីយត្រួតពិនិត្យគុណភាពខ្យល់ គឺស្របគ្នាជាមួយនឹងបទដ្ឋានអន្តរជាតិផងដែរ។
- **របាយការណ៍នេះ គឺជាប្រភពព័ត៌មានដ៏សំខាន់ដែលផ្តល់ជូននូវទស្សនៈដ៏មានតម្លៃ ដល់ស្ថាប័នរដ្ឋាភិបាលទីភ្នាក់ងារបរិស្ថាន និងសាធារណជន។** តាមរយៈការបណ្តុះស្មារតីតម្លាភាព និងការផ្សព្វផ្សាយចំណេះដឹងអំពីស្ថានភាព នៃការតាមដានត្រួតពិនិត្យគុណភាពខ្យល់នៅកម្ពុជារបាយការណ៍នេះ ជួយសម្របសម្រួលដល់ការយល់ដឹងរួមអំពីបញ្ហាប្រឈមនិងឱកាសនៅក្នុងផ្នែកដឹកនាំបរិស្ថាន។
- **លទ្ធផលនៃការវាយតម្លៃនេះ ក៏នឹងដើរតួនាទីជាធាតុចូលដ៏មានតម្លៃ សម្រាប់ការរៀបចំសៀវភៅណែនាំស្តីពីនីតិវិធីធានាគុណភាព និងការត្រួតពិនិត្យគុណភាព (QA & QC)** ដែលអាចបញ្ជ្រាបចូលទៅក្នុងនាយកដ្ឋានគ្រប់គ្រងគុណភាព ខ្យល់ រំញ័រ និងសំឡេងរបស់ក្រសួងបរិស្ថាន។

## ១.៣ វិសាលភាព និងដែនកំណត់នៃការសិក្សា

ឧបករណ៍សិនស័រ និងស្ថានីយតាមដានត្រួតពិនិត្យគុណភាពខ្យល់ ត្រូវបានដំឡើងនៅទូទាំងប្រទេស។ ទោះជាយ៉ាងនេះក្តីដោយសារតែឧបសគ្គផ្នែកថវិកា និងពេលវេលាមានកំណត់ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងនៅក្នុងខេត្តគោលដៅចំនួនបីដែលបានជ្រើសរើសជាសំណាកគំរូសាកល្បងដែលតំណាងឱ្យខេត្តក្រុងផ្សេងៗទៀត។ ក្រុងទាំងនេះរួមមានដូចជា ក្រុងសៀមរាប រាជធានីភ្នំពេញ និងក្រុងព្រះសីហនុ។

តាមបច្ចេកទេស នាឡិកាស្ទង់លំហូរឌីជីថល គឺត្រូវការចាំបាច់ដើម្បីវាស់ស្ទង់អត្រាលំហូរខ្យល់របស់ឧបករណ៍។ ជាទូទៅសមត្ថភាពរបស់ម៉ាស៊ីនបូមមានការប្រែប្រួលទៅតាមអាយុកាលរបស់ឧបករណ៍។ដោយសារតែមិនមាននាឡិកាស្ទង់លំហូរឌីជីថល វិធីសាស្ត្រផ្ទៀងផ្ទាត់បន្សីទិន្នន័យ[2] ត្រូវបានយកមកអនុវត្តសម្រាប់ការសិក្សានេះ។ វិធីសាស្ត្រនេះ ជួយឱ្យយើងមិនចាំបាច់ធ្វើការពិចារណាទៅលើសមត្ថភាពម៉ូទ័របូម ដោយសារតែវិធីសាស្ត្រនេះផ្តោតតែទៅលើទិន្នន័យ ជាជាងការផ្តោតទៅលើសិនស័រ ឬម៉ូទ័របូមដោយផ្ទាល់។

## ១.៤ រចនាសម្ព័ន្ធនៃរបាយការណ៍

របាយការណ៍នេះបែងចែកជា ៤ ជំពូក រួមមាន៖

**ជំពូក ១៖** សារតារ - សេចក្តីផ្តើមដែលប្រាប់ពីគោលបំណងនៃរបាយការណ៍ វិសាលភាព និងដែនកំណត់នៃការសិក្សា និងគូសបញ្ជាក់អំពីការរៀបចំ។

**ជំពូក ២៖** ការប្រមូលទិន្នន័យ - ព័ត៌មានលម្អិតអំពីវិធីសាស្ត្រ និងនីតិវិធីដែលបានអនុវត្តនៅក្នុងការប្រមូលទិន្នន័យអំពីគុណភាពខ្យល់ និងស្វែងយល់ពីឧបករណ៍ និងបច្ចេកវិទ្យាពាក់ព័ន្ធនៅក្នុងដំណើរការនេះ។

**ជំពូក ៣៖** របាយការណ៍វាយតម្លៃ - បង្ហា អំពីការវាយតម្លៃលម្អិតអំពីស្ថានភាពបច្ចុប្បន្ននៃត្រួតពិនិត្យគុណភាពខ្យល់ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់នៅក្នុងខេត្តសៀមរាប រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ដោយវិភាគអំពីទិដ្ឋភាពសំខាន់ៗដូចជាហេដ្ឋារចនាសម្ព័ន្ធ សមត្ថភាពបច្ចេកទេស ការគ្រប់គ្រងទិន្នន័យ និងប្រសិទ្ធភាពប្រតិបត្តិការទាំងមូល។

**ជំពូក ៤៖** អនុសាសន៍ - ផ្តល់អនុសាសន៍ដែលអាចយកទៅអនុវត្តបាន ដែលបានមកពីការវាយតម្លៃ ដោយស្នើឡើងនូវកិច្ចអន្តរាគមន៍ជាយុទ្ធសាស្ត្រ និងការកែលម្អក្នុងគោលបំណងពង្រឹងប្រសិទ្ធភាព។

---

2 វិធីសាស្ត្រផ្ទៀងផ្ទាត់បន្សីទិន្នន័យ (collocation) គឺជាវិធីសាស្ត្រមួយសម្រាប់ការវិភាគដើម្បីធ្វើព្យាសកម្ម ដែលតម្រូវអោយយក ឧបករណ៍សិនស័រមកដាក់ជិតគ្នាជាមួយនិងស្ថានីយបង្អែក ដើម្បីប្រៀបធៀបទិន្នន័យ និងធានាភាពស្របគ្នា ។

# ២. ការប្រមូលទិន្នន័យ

## ២.១ ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់

ជាទូទៅនៅក្នុងប្រទេស មានស្ថានីយត្រួតពិនិត្យគុណភាពខ្យល់ពីរប្រភេទ៖ ស្ថានីយបង្អែក និងសិនស័រតម្លៃទាប។ ស្ថានីយទាំងពីរនេះ មានគុណសម្បត្តិនិងគុណវិបត្តិរៀងៗខ្លួន។ ដូច្នេះស្ថានីយទាំងពីរនេះត្រូវបានប្រើប្រាស់ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមកដើម្បីបង្កើនប្រសិទ្ធភាពថ្លៃចំណាយ។

### ស្ថានីយបង្អែក

ត្រួតពិនិត្យគុណភាពខ្យល់ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់បង្អែកគឺជាមូលដ្ឋានឯកទេសដែលរចនាឡើងដើម្បីវាស់ស្ទង់សារធាតុបំពុលខ្យល់សំខាន់ៗជាប្រព័ន្ធនិងយ៉ាងសុក្រឹតនៅក្នុងបរិយាកាសជុំវិញ។ដោយមានទីតាំងជាយុទ្ធសាស្ត្រនៅតាមទីតាំងតំណាងឱ្យគុណភាពខ្យល់បរិយាកាសជាទូទៅស្ថានីយទាំងនេះដើរតួនាទីជាបន្ទាត់គោលសម្រាប់ការវាយតម្លៃលក្ខខណ្ឌបរិយាកាស និងធានាបាននូវភាពជឿជាក់ទៅលើទិន្នន័យគុណភាពខ្យល់។

ដោយបំពាក់ជាមួយនូវឧបករណ៍ទំនើប ត្រួតពិនិត្យគុណភាពខ្យល់ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់បង្អែក មាននូវបច្ចេកវិទ្យាទំនើបដើម្បីវាស់ស្ទង់សារធាតុបំពុលដូចជា PM2.5, PM10, NO2, SO2, CO, O3 និងប៉ារ៉ាម៉ែត្រឧតុនិយម។ មូលដ្ឋាននេះប្រកាន់ខ្ជាប់តាមនីតិវិធីព្យាសកម្ម និងការថែទាំយ៉ាងតឹងរ៉ឹងនិងទៀងទាត់ ដោយផ្តល់នូវទិន្នន័យស្តង់ដារ និងត្រឹមត្រូវ ដែលសំខាន់សម្រាប់ការប្រតិបត្តិតាមបទប្បញ្ញត្តិ និងការស្រាវជ្រាវវិទ្យាសាស្ត្រ។

*រូបភាព ១. ការផ្ទៀងផ្ទាត់ទិន្នន័យស្ថានីយបង្អែក និងសិនស័រ*



**ស្ថានីយបង្អែក មានអត្ថប្រយោជន៍ជាច្រើនដូចជា៖**

- **សុក្រឹតភាពទិន្នន័យ៖** ស្ថានីយបង្អែកធានាបាននូវសុក្រឹតភាព និងភាពជឿទុកចិត្តបានទៅលើទិន្នន័យគុណភាពខ្យល់ ដោយបង្កើតជាបន្ទាត់គោលសម្រាប់ការវាស់ស្ទង់ដែលមានសង្គតិភាព។
- **អនុលោមភាពនៃបទប្បញ្ញត្តិ៖** ស្ថានីយបង្អែក មានសារៈសំខាន់សម្រាប់ការបង្កើត និងការវាយតម្លៃស្តង់ដារ និងបទប្បញ្ញត្តិស្តីពីគុណភាពខ្យល់ ដោយចូលរួមចំណែកដល់ការធ្វើសេចក្តីសម្រេចចិត្តតាមបទប្បញ្ញត្តិ។
- **ការស្រាវជ្រាវវិទ្យាសាស្ត្រ៖** អ្នកស្រាវជ្រាវប្រើប្រាស់ទិន្នន័យពីស្ថានីយបង្អែកដើម្បីអនុវត្តការសិក្សាស៊ីជម្រៅអំពីផលប៉ះពាល់នៃការបំពុលខ្យល់ ដែលរួមចំណែកដល់ការយល់ដឹងកាន់តែស៊ីជម្រៅអំពីផលប៉ះពាល់នៃបរិស្ថានទៅលើមនុស្ស។
- **ការការពារសុខភាពសាធារណៈ៖** តាមរយៈការផ្តល់ទិន្នន័យភ្លាមៗ អំពីគុណភាពខ្យល់ស្ថានីយបង្អែក ជួយឱ្យមានការធ្វើអន្តរាគមន៍ទាន់ពេលវេលា ដើម្បីការពារសុខភាពសាធារណៈពីគ្រោះថ្នាក់ដែលអាចកើតមានឡើង ពាក់ព័ន្ធនឹងកម្រិតសារធាតុពុលដែលកើនឡើង។
- **ការប្រៀបធៀបអន្តរជាតិ៖** ត្រួតពិនិត្យគុណភាពខ្យល់ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់បង្អែកសម្របសម្រួលដល់កិច្ចសហការជាសកល តាមរយៈការផ្តល់ទិន្នន័យស្តង់ដារ ដែលអាចយកមកធ្វើការប្រៀបធៀបគ្នាបានរវាងបណ្តាប្រទេស និងជួយដល់ការដោះស្រាយបញ្ហាបំពុលខ្យល់ឆ្លងដែន។

ជាមូលដ្ឋាន ត្រួតពិនិត្យគុណភាពខ្យល់ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់បង្អែក គឺជាសមាសធាតុដ៏សំខាន់នៃការគ្រប់គ្រងគុណភាពខ្យល់ ដោយធានាបាននូវការប្រមូលទិន្នន័យប្រកបដោយភាពត្រឹមត្រូវ ទំនុកចិត្ត និងគ្រប់ជ្រុងជ្រោយ ដែលមានសារៈសំខាន់សម្រាប់ការការពារសុខភាពសាធារណៈ និងគាំទ្រដល់គោលនយោបាយបរិស្ថាន។

នៅក្នុងការវាយតម្លៃនេះ យើង សន្មត់ថាស្ថានីយបង្អែកទទួលបានការថែទាំ និងព្យាសកម្មបានទៀងទាត់ និងត្រឹមត្រូវ ដោយមានជំនាញការជនជាតិចិនធ្វើការត្រួតពិនិត្យ និងព្យាសកម្មជាប្រចាំខែចាប់តាំងពីពេលដំឡើងដំបូង។ បន្ទាប់ពីនោះសកម្មភាពចម្បងៗចំនួនបីបានអនុវត្តនៅស្ថានីយបង្អែក៖

- ការត្រួតពិនិត្យទិន្នន័យព្យាសកម្មដែលបានកត់ត្រា ដើម្បីស្វែងយល់អំពីរបៀបដំណើរការនៃឧបករណ៍។
- ការអង្កេតទិន្នន័យគុណភាពខ្យល់ ក្នុងករណីដែលមានទិន្នន័យខុសប្រក្រតី ចាំបាច់ត្រូវធ្វើការសម្អាត។
- ការប្រើប្រាស់ទិន្នន័យនៅស្ថានីយបង្អែកជាបន្ទាត់គោល និងការភ្ជាប់សិនស័រតម្លៃទាប់សម្រាប់គោលបំណងផ្ទៀងផ្ទាត់។

## ឧបករណ៍សិនស័រគុណភាពខ្យល់តម្លៃទាប

សិនស័រតម្លៃទាបសម្រាប់ការត្រួតពិនិត្យគុណភាពខ្យល់ សំដៅលើឧបករណ៍តម្លៃសមរម្យ និងអាចចល័តបានដែលត្រូវបានរចនាឡើងដើម្បីវាស់ស្ទង់ប៉ារ៉ាម៉ែត្រខ្យល់ជាច្រើន។ សិនស័រទាំងនេះ គឺជាជម្រើសនៃប្រសិទ្ធភាពថ្លៃចំណាយបើធៀបទៅនឹងឧបករណ៍វាស់ស្ទង់ធម្មតាដែលអាចឱ្យយើងធ្វើការបំពាក់បាននៅក្នុងបរិស្ថានផ្សេងជាច្រើនប្រភេទ។ ទោះបីជាភាពត្រឹមត្រូវនៃសិនស័រនេះ មានកំណត់ បើធៀបទៅនឹងឧបករណ៍កម្រិតបង្អែក សិនស័រតម្លៃទាបដើរតួនាទីយ៉ាងសំខាន់នៅក្នុងការពង្រីកការគ្របដណ្តប់តាមទីកន្លែងនៃបណ្តាញត្រួតពិនិត្យគុណភាពខ្យល់។

សិនស័រទាំងនេះជាទូទៅ មានរូបរាងតូចទម្ងន់ស្រាល និងងាយស្រួលដំឡើងដែលធ្វើឱ្យសិនស័រនេះសមស្របបំផុតសម្រាប់ការត្រួតពិនិត្យដែលត្រូវបានបែងចែកទៅតាមតំបន់ទីក្រុង និងជនបទ។ ដោយបំពាក់ជាមួយនឹងសិនស័រសម្រាប់ភាគល្អិតនិចល (PM2.5 និង PM10) ឧស្ម័ន (CO, NO2, SO2, O3) និងប៉ារ៉ាម៉ែត្រពាក់ព័ន្ធផ្សេងទៀត ឧបករណ៍សិនស័រតម្លៃទាប ជាញឹកញាប់រួមមានប្រភពថាមពលពីពន្លឺព្រះអាទិត្យឬថាមពលអគ្គិសនីសម្រាប់ការដំណើរការជាប់ជានិច្ច។ ខណៈពេលដែលសិនស័រទាំងនេះ អាចមិនមានភាពភាពស្មុកស្មាញដូចស្ថានីយបង្អែកភាពបត់បែន និងតម្លៃសមរម្យនេះសិនស័រទាំងនេះ ធ្វើឱ្យវាក្លាយជាឧបករណ៍ដែលមានតម្លៃសម្រាប់ការចាប់យកទិន្នន័យបម្រែបម្រួលគុណភាពខ្យល់តាមមូលដ្ឋាន។

> «ទោះបីជាភាពត្រឹមត្រូវនៃសិនស័រនេះ មានកំណត់ បើធៀបទៅនឹងឧបករណ៍កម្រិតបង្អែក សិនស័រតម្លៃទាបដើរតួនាទីយ៉ាងសំខាន់នៅក្នុងការពង្រីកការគ្របដណ្តប់តាមទីកន្លែងនៃបណ្តាញត្រួតពិនិត្យគុណភាពខ្យល់។»

សិនស័រតម្លៃទាប មានពីរប្រភេទ គឺ GRI-IAT[3] និង Oceanus ដែលត្រូវបានដំឡើងនៅទូទាំងប្រទេស។ GRI-IAT ជាឧបករណ៍មានទំហំតូច និងទម្ងន់ស្រាល ងាយស្រួលក្នុងការចល័ត។ Oceanus មានទម្ងន់ធ្ងន់ជាងបន្តិច ដោយផ្លាស់ប្តូរពីប្រភពថាមពលពន្លឺព្រះអាទិត្យទៅប្រើប្រាស់ប្រភពថាមពលអគ្គិសនី ដោយសារតែកង្វះថាមពលពាក់ព័ន្ធនឹងបន្ទះសូឡា។ សិនស័រទាំងពីរនេះ មានប្រភពមកពីប្រទេសចិន រួមបញ្ចូលសិនស័រភាគល្អិតនិចល និងសិនស័រអេឡិចត្រូគីមី (កាបូនម៉ូណូអុកស៊ីត (CO), នីត្រូសែនឌីអុកស៊ីត (NO2) ស្ពាន់ធ័រឌីអុកស៊ីត (SO2) និងអូហ្សូន (O3)) និង សិនស័របន្ថែមដូចជា សំណើមសីតុណ្ហភាព និងសមាសធាតុសរីរាង្គងាយប្រែប្រួល(VOC)។ បច្ចុប្បន្ន មានតែសិនស័រភាគល្អិតនិចលប៉ុណ្ណោះដែលកំពុងដំណើរការ ដោយសារតែសិនស័រអេឡិចត្រូគិមីផុតសុពលភាព។

| សិនស័រតម្លៃទាប មានទំហំតូច | សិនស័រតម្លៃទាប មានទម្ងន់ស្រាល | សិនស័រតម្លៃទាប ងាយស្រួលក្នុងការចល័ត |
| --- | --- | --- |

3 ម៉ាករបស់ឧបករណ៍សិនស័រនេះ គឺ GRI និង IAT ពោលគឺ ឧបករណ៍វាស់ស៊ីតុណ្ហភាពខ្យល់ក្នុងបំពង់ស្រូបខ្យល់

*រូបភាព ២. សិនស័រតម្លៃទាប (Oceanus និង GRI-IAT)*




ការប្រើប្រាស់សិនស័រតម្លៃទាបមានគុណសម្បត្តិមួយចំនួនដូចជា៖

- **បង្កើនការគ្របដណ្តប់តាមទីតាំង៖** សិនស័រតម្លៃទាប ជួយដល់ការបង្កើតបណ្តាញតាមដានត្រួតពិនិត្យកាន់តែញឹកដែលផ្តល់នូវការយល់ដឹងកាន់តែលម្អិតបន្ថែមទៀតអំពីបម្រែបម្រួលគុណភាពខ្យល់នៅទូទាំងទីតាំងខុសៗគ្នា។
- **ការចូលរួមរបស់សហគមន៍៖** តម្លៃសមរម្យ និងភាពសាមញ្ញនៃសិនស័រទាំងនេះ ជួយសម្របសម្រួលគំនិតផ្តួចផ្តើម តាមដានត្រួតពិនិត្យនៅតាមសហគមន៍ដែលពង្រឹងសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ឱ្យចូលរួមយ៉ាងសកម្មនៅក្នុងការវាយតម្លៃ និងដោះស្រាយក្តីបារម្ភអំពីគុណភាពខ្យល់នៅក្នុងមូលដ្ឋាន។
- **ការដំឡើងរហ័ស៖** ភាពងាយស្រួលក្នុងការដំឡើងនៃសិនស័រទាំងនេះ ជួយឱ្យមានការឆ្លើយតបកាន់តែរហ័សចំពោះបញ្ហាប្រឈមផ្នែកបរិស្ថានដែលកើតឡើងថ្មីៗដែលជួយឱ្យ យើងអាចប្រមូលទិន្នន័យបានទាន់ពេលវេលា ក្នុងអំឡុងព្រឹត្តិការណ៍ដូចជា ភ្លើងឆេះព្រៃ ឧប្បត្តិហេតុឧស្សាហកម្ម ឬការប្រែប្រួលភ្លាមៗ លើប្រភពបំពុល។
- **បំពេញបន្ថែមឱ្យស្ថានីយបង្អែក៖** ដោយមិនមែនជាការជំនួសឱ្យស្ថានីយបង្អែកសិនស័រតម្លៃទាបនេះ បំពេញបន្ថែមទៅឱ្យហេដ្ឋារចនាសម្ព័ន្ធត្រួតពិនិត្យបែបប្រពៃណី តាមរយៈការផ្តល់នូវចំណុចទិន្នន័យបន្ថែម ជាពិសេសនៅតាមតំបន់ដែលមិនមានលទ្ធភាពទទួលបានឧបករណ៍កម្រិតបង្អែកបាន។
- **ការស្រាវជ្រាវនិងការយល់ដឹង៖** សិនស័រតម្លៃទាប រួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាគុណភាពខ្យល់។ សិនស័រទាំងនេះ ដើរតួនាទីជាឧបករណ៍អប់រំ និងមានសារៈសំខាន់ខ្លាំងក្នុងការគូសបញ្ជាក់ពីប្រភព និងនិន្នាការបំពុលនៅក្នុងសហគមន៍។

ជាទូទៅ សិនស័រតម្លៃទាបសម្រាប់ការត្រួតពិនិត្យគុណភាពខ្យល់ បំពេញចន្លោះខ្វះខាតរវាងការគ្របដណ្តប់រាយប៉ាយរបស់ស្ថានីយបង្អែកនិងតម្រូវការទិន្នន័យភ្លាមៗនៅតាមមូលដ្ឋាន។ តម្លៃសមរម្យ និងភាពបត់បែនធ្វើឱ្យសិនស័រទាំងនេះ ជាទ្រព្យសកម្មដ៏មានតម្លៃនៅក្នុងការបង្កើតការយល់ដឹងកាន់តែគ្រប់ជ្រុងជ្រោយបន្ថែមទៀត អំពីបម្រែបម្រួលគុណភាពខ្យល់ ដែលពង្រឹងសិទ្ធិអំណាចរបស់សហគមន៍និងចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវបរិស្ថានកាន់តែទូលំទូលាយ។

នៅក្នុងការសិក្សានេះសិនស័រតម្លៃទាបត្រូវបានធ្វើការអង្កេតដោយផ្ទាល់និងបន្ទាប់មកត្រូវបានដោះចេញដើម្បីយកទៅតភ្ជាប់ទៅនឹងស្ថានីយបង្អែកសម្រាប់ដំណើរការផ្ទៀងផ្ទាត់។ នៅពេលដែលបញ្ចប់ដំណើរការផ្ទៀងផ្ទាត់ សិនស័រ តម្លៃទាបនឹងត្រូវបានដោះចេញពីស្ថានីយបង្អែក និងដំឡើងឡើងវិញនៅទីតាំងដើម។

## ២.២ នីតិវិធីថែទាំ និងព្យាសកម្ម

ឧបករណ៍សិនស័រនៃប្រព័ន្ធត្រួតពិនិត្យគុណភាពខ្យល់ តម្រូវឱ្យមានការថែទាំ និងព្យាសកម្មដើម្បីធានាថាទិន្នន័យអាចទុកចិត្តបាន។ ការថែទាំរួមមាន ការត្រួតពិនិត្យលើផ្នែកនានា ដើម្បីធានាថាសិនស័រដំណើរការបានត្រឹមត្រូវ រួមទាំងការសម្អាតផងដែរ។ ម្យ៉ាងវិញទៀត ការព្យាសកម្ម គឺជាដំណើរការនៃការកែតម្រូវ ឬលៃតម្រូវលើការវាស់វែងដោយសិនស័រ ដោយប្រៀបធៀបវាទៅនឹងកំហាប់យោងនៃប៉ារ៉ាម៉ែត្រដែលបានស្គាល់។ ដំណើរការនេះ គឺក្នុងគោលបំណងបង្កើនសុក្រឹតភាពរបស់សិនស័រ តាមរយៈការធ្វើតេស្តជាច្រើនទាំងនៅក្នុងមន្ទីរពិសោធន៍ និងនៅតាមទីតាំងដំឡើងជាក់ស្តែង។ ព្យាសកម្ម ដើរតួនាទីជាសមាសធាតុដ៏សំខាន់មួយនៃការគ្រប់គ្រងគុណភាពរបស់សិនស័រដែលជួយកំណត់ និងលុបបំបាត់ការទិន្នន័យជាន់គ្នា ដែលជាលទ្ធផល ជួយរក្សាបាននូវសុក្រឹតភាព និងសង្គតិភាពនៃទិន្នន័យដែលប្រមូលបាន។ សៀវភៅណែនាំស្តីពីការថែទាំ និងព្យាសកម្ម នឹងត្រូវរៀបចំឡើងនៅពេលក្រោយនៅក្នុងគម្រោងនេះ។

ដំណើរការថែទាំ និងព្យាសកម្ម គឺជាជំហានដ៏សំខាន់នៅក្នុងការធានាថាឧបករណ៍នៅតែស្ថិតក្នុងស្ថានភាពត្រឹមត្រូវ និងអាចធានាបាននូវគុណភាពទិន្នន័យ។ ទោះជាយ៉ាងនេះក្តី ដំណើរការទាំងនេះ នាំឱ្យមានកិច្ចការបន្ថែមទៀតចំពោះប្រតិបត្តិការជាប្រចាំ ដែលអនុវត្តដោយមន្ត្រីបច្ចេកទេស។ ទំនួលខុសត្រូវបន្ថែមនេះ អាចកាន់តែមានភាពស្មុគស្មាញ និងចំណាយពេលវេលាច្រើន ដែលទាមទារឱ្យអនុវត្តតាមនីតិវិធីលម្អិត និងចំណាយពេលវេលាយូរ។ ផ្នែកខាងក្រោមនេះគូសបញ្ជាក់អំពីចំណុចខ្លាំង និងចំណុចខ្សោយពាក់ព័ន្ធនឹងការប្រកាន់ខ្ជាប់តាមពិធីសាស្ត្រថែទាំ និងព្យាសកម្ម។

**ចំណុចខ្លាំង**

- **ដំណើរការថែទាំ៖** ដំណើរការនេះ រួមបញ្ចូលការកំណត់ការងារការរៀបចំផែនការការកំណត់កាលវិភាគ និងការអនុវត្ត។ ការថែទាំធ្វើឱ្យសិនស័រមានប្រសិទ្ធភាព(មានស្ថានភាពដំណើរការល្អប្រសើរ)និងមានប្រសិទ្ធភាពថ្លៃចំណាយ។
- **នីតិវិធីព្យាសកម្ម៖** ធានាបាននូវការផលិតទិន្នន័យដែលអាចទុកចិត្តបាននិងចៀសវាងកំហុស។ នៅពេលដែលធ្វើការរួមបញ្ចូលទិន្នន័យពីសិនស័រច្រើននីតិវិធីនេះ ធានាបាននូវស្ថានភាពទិន្នន័យក្នុងទម្រង់តែមួយដូចគ្នា និងសង្គតិភាពនៃសិនស័រទាំងអស់។
- **ការវិភាគទិន្នន័យ/ការធ្វើសុពលកម្ម៖** ដំណើរការនេះ រួមបញ្ចូលការវិភាគ និងការផ្ទៀងផ្ទាត់ទិន្នន័យ និងលទ្ធផល។ ដំណើរការនេះតំណាងឱ្យជំហានចុងក្រោយ មុនពេលស្នើសុំការអនុម័ត និងជាជំហានដ៏សំខាន់សម្រាប់ការក្សាឱ្យបាននូវគុណភាពទិន្នន័យ។

**ចំណុចខ្សោយ**

- **ការចំណាយពេលវេលានិងកម្លាំងកាយ៖** ដំណើរការថែទាំជារឿយៗរួមបញ្ចូលនូវការអនុវត្តតាមសៀវភៅណែនាំលម្អិតមួយជំហានម្តងៗ។ ការរៀបចំផែនការ និងការកំណត់កាលវិភាគ ក៏បន្ថែមបន្ទុកការងារផងដែរ ដែលធ្វើឱ្យការងារនេះត្រូវចំណាយពេលវេលាច្រើន។
- **ឧបសគ្គថវិកា៖** ការកំណត់កាលវិភាគថែទាំឱ្យបានត្រឹមត្រូវទាមទារឱ្យមានថវិកាសម្រាប់ការជួសជុល ឬការផ្លាស់ប្តូរគ្រឿងបន្លាស់ និងគាំទ្រដល់ការធ្វើដំណើរផងដែរ។ ទោះបីជាឧបសគ្គថវិកាជារឿយៗ ត្រូវបានគេមើលឃើញថាជាចំណុចខ្សោយក្តីក៏ឧបសគ្គទាំងនេះ គួរតែត្រូវចាត់ទុកថាជាចំណុចខ្លាំងដោយសារតែប្រសិទ្ធភាពថ្លៃចំណាយនៃការថែទាំ។
- **ផលវិបាក៖** ដំណើរការនីមួយៗ មានច្រើនជំហាន ចាប់តាំងពីបញ្ជីត្រួតពិនិត្យដំបូង រហូតដល់ការផ្ទៀតផ្ទាត់នៅពេលបញ្ចប់។ ការអនុវត្តតាមជំហានទាំងនេះដោយយកចិត្តទុកដាក់ គឺមានសារៈសំខាន់ណាស់ ដើម្បីចៀសវាងការធ្វេសប្រហែសលើការងារប៉ុន្តែវាក៏អាចចំណាយពេលវេលាច្រើន និងទាមទារឱ្យមានការអត់ធ្មត់ផងដែរ។

## ២.៣ ទីតាំងអង្កេតគោលដៅ

នៅកម្ពុជា មានស្ថានីយត្រួតពិនិត្យគុណភាពខ្យល់សរុបចំនួន ៥០ កន្លែង ដែលរួមបញ្ចូលទាំងស្ថានីយបង្អែក និងសិនស័រតម្លៃទាប។ គួរឱ្យកត់សម្គាល់ផងដែរស្ថានីយបង្អែកចំនួន១០ត្រូវបានដំឡើងនៅឆ្នាំ ២០២០ តាមរយៈការផ្តល់ជំនួយពីសាធារណរដ្ឋប្រជាមានិតចិន។ លើសពីនេះ សិនស័រតម្លៃទាប គឺត្រូវបានដំឡើងនៅចន្លោះឆ្នាំ ២០១៨ និងឆ្នាំ ២០១៩ ដែលជាទូទៅមានសិនស័រចំនួនពីរក្នុងមួយខេត្ត ឬក្រុងនីមួយៗ។

*រូបភាព ៣. របាយទីតាំងស្ថានីយត្រួតពិនិត្យគុណភាពខ្យល់នៅកម្ពុជា (ផែនការខ្យល់ស្អាតកម្ពុជា)*




ទីតាំងរបស់ស្ថានីយបង្អែក គឺសុទ្ធតែមានភាពជាយុទ្ធសាស្ត្រ ដែលទីតាំងទាំងនោះ មាននៅតាមទីក្រុងធំៗ និងខេត្តសំខាន់ៗ។ ស្ថានីយបង្អែកទាំងនេះ ក៏ត្រូវបានបំពាក់នូវសមត្ថភាពតាមដានត្រួតពិនិត្យគុណភាពខ្យល់ជុំវិញបានយ៉ាងគ្រប់ជ្រុងជ្រោយ រួមទាំងឧស្ម័នកាបូនម៉ូណូអុកស៊ីត(CO)ស្ពាន់ធ័រឌីអុកស៊ីត(SO2)នីត្រូសែនអុកស៊ីត/ឌីអុកស៊ីត/នីទ្រិច(NO/NO2/NOx) អូហ្សូន (O3) ភាគល្អិតនិចល PM2.5, PM10 និងទិន្នន័យឧតុនិយម (សំណើម ល្បឿនខ្យល់ ទិសដៅខ្យល់ និងសម្ពាធ)។ ស្ថានីយទាំងនេះឆ្លងកាត់ការថែទាំនិងព្យាសកម្មជាទៀងទាត់ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍។កំណត់ត្រាការថែទាំរួមទាំងព័ត៌មានលម្អិតអំពីការព្យាសកម្ម គឺត្រូវបានកត់ត្រាទុកដោយយកចិត្តទុកដាក់នៅក្នុងសៀវភៅបញ្ជីកំណត់ត្រានៅតាមស្ថានីយនីមួយៗ។

ការអង្កេតសិនស័រនេះ គ្របដណ្តប់លើទីតាំងសំខាន់ៗចំនួនបីនៅក្នុងប្រទេសកម្ពុជា៖រាជធានីភ្នំពេញ ខេត្ត សៀមរាប និងខេត្តព្រះសីហនុ។ នៅតាមទីតាំងនីមួយៗមានការត្រួតពិនិត្យទៅលើស្ថានីយចំនួនបីដែលរួមមានស្ថានីយបង្អែកចំនួនមួយ និងសិនស័រតម្លៃទាបចំនួនពីរ(GRI-IAT និង Oceanus)។ ការអង្កេតផ្តោតជាចម្បងលើការវាយតម្លៃលក្ខខណ្ឌរូបសាស្ត្រ មុខងារដំណើរការ និងការបញ្ចេញទិន្នន័យរបស់សិនស័រ។

## ២.៤ ការគ្រប់គ្រងទិន្នន័យ

ការគ្រប់គ្រងទិន្នន័យនៃបណ្តាញស្ថានីយត្រួតពិនិត្យគុណភាពខ្យល់ ត្រូវបានកំណត់លក្ខណៈដោយប្រព័ន្ធដែលមានរចនាសម្ព័ន្ធល្អ និងមានលក្ខណៈសហការ។ ទិន្នន័យដែលបង្កើតឡើងដោយស្ថានីយបង្អែកទាំងដប់ ដែលបំពាក់ជាមួយនឹង

សមត្ថភាពតាមដានត្រួតពិនិត្យគ្រប់ជ្រុងជ្រោយ ត្រូវបានរក្សាទុកជាប្រព័ន្ធនៅក្នុងមជ្ឈមណ្ឌលទិន្នន័យដែលមានទីតាំងស្ថិត នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ ពេញមួយរយៈពេលគម្រោង មជ្ឈមណ្ឌលនេះ ត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពដោយម៉ាស៊ីនមេពីប្រទេសចិន ដែលធានាបាននូវហេដ្ឋារចនាសម្ព័ន្ធរក្សាទុកដ៏រឹងមាំ និងអាចទុកចិត្តបាន។ អ្វីដែលសំខាន់ផងដែរនោះ មន្ត្រីមកពីក្រសួង ក៏បានទទួលអត្ថប្រយោជន៍ពីការចូលប្រើប្រាស់មជ្ឈមណ្ឌល ទិន្នន័យនេះដោយសេរីផងដែរ ដែលជាការលើកកម្ពស់តម្លាភាព និងលទ្ធភាពក្នុងការចូលទៅប្រើប្រាស់។ ក្រោយបញ្ចប់គម្រោងនេះ យើងរំពឹងទុកថានឹងមានការផ្លាស់ប្តូរដ៏សំខាន់មួយ ដោយសារតែកម្មសិទ្ធិនៃមជ្ឈមណ្ឌលទិន្នន័យនេះ ត្រូវបានកំណត់ឱ្យផ្ទេរទៅឱ្យក្រសួង ដើម្បីធានាបាននូវការបន្តទទួលយកទំនួលខុសត្រូវក្នុងការគ្រប់គ្រងទិន្នន័យ។

បន្ថែមពីលើស្ថានីយបង្អែក ម៉ាស៊ីនមេដាច់ដោយឡែកមួយដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន(MOE) ដើរតួនាទីដ៏សំខាន់នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនេះ។ ម៉ាស៊ីនមេ នេះទទួល និងវិភាគទិន្នន័យប្រកបដោយប្រសិទ្ធភាព ពីសិនស័រតម្លៃទាបទាំងអស់ដែលបានដំឡើងនៅទូទាំងប្រទេស។ ដំណើរការដែលមានប្រសិទ្ធភាពនេះ ជួយឱ្យមន្ត្រីធ្វើការវិភាគ និងផ្ទៀងផ្ទាត់លទ្ធផលបានភ្លាមៗ ដែលចូលរួមចំណែកដល់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព។ លើសពីនេះ ក្រសួងបរិស្ថាន បង្ហាញអំពីការប្តេជ្ញាចិត្តចំពោះតម្លាភាព ដោយរៀបចំការបង្ហាញទិន្នន័យ ភ្លាមៗពីបណ្តាញស្ថានីយត្រួតពិនិត្យគុណភាពខ្យល់នៅទូទាំងប្រទេសតាមរយៈ**គេហទំព័រ៖airquality.moe.gov.kh/home**។ វេទិកាផ្សព្វផ្សាយសាធារណៈ នេះបម្រើដល់ការបង្កើនការយល់ដឹង និងការស្វែងយល់អំពីស្ថានភាពគុណភាពខ្យល់ដោយបណ្តុះនូវវប្បធម៌នៃការថែទាំបរិស្ថានឱ្យបានគ្រប់ជ្រុងជ្រោយ។

## ២.៥ សមត្ថភាពបច្ចេកទេស

ការចូលរួមជាមួយមន្ត្រីបច្ចេកទេស និងថ្នាក់គ្រប់គ្រងកណ្តាល ក៏ត្រូវបានអនុវត្តដោយផ្តោតទៅលើគោលនយោបាយដែលមានស្រាប់ ការគ្រប់គ្រងទិន្នន័យ និងការអនុវត្តផ្នែកបច្ចេកទេស។ ទិដ្ឋភាពសំខាន់ៗចំនួនបី គឺត្រូវបានលើកមកពិភាក្សា ដើម្បីធានាបាននូវគុណភាពទិន្នន័យ៖

- **សកម្មភាពប្រមូលទិន្នន័យ៖** ការធានាធ្វើយ៉ាងណាឱ្យសិនស័រដំណើរការបានត្រឹមត្រូវ និងកត់ត្រាទិន្នន័យបានសុក្រឹត។
- **សកម្មភាពវិភាគទិន្នន័យ៖** ការយល់ដឹងអំពីនិន្នាការទិន្នន័យដោយគូសបញ្ជាក់អំពីដំណើរការវិភាគ និងការអនុវត្តវិធានការផ្ទៀងផ្ទាត់។
- **នីតិវិធីដោះស្រាយបញ្ហា៖** ការដោះស្រាយបញ្ហានានា រួមមានសិនស័រអគ្គិសនី អេឡិចត្រូនិក (ម្តងម្កាល) និងទាមទារឱ្យមានជំនាញផ្នែកឌីជីថល និងព័ត៌មានវិទ្យាដើម្បីជំរុញដល់ការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព។

តាមរយៈការលើកឡើងអំពីសមាសធាតុទាំងនេះ របាយការណ៍នេះ មានគោលបំណងបង្កើតនូវមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់គំនិតផ្តួចផ្តើមត្រួតពិនិត្យគុណភាពខ្យល់ជាបន្តបន្ទាប់នៅកម្ពុជា។

## ៣. ការវាយតម្លៃស្ថានីយត្រួតពិនិត្យគុណភាពខ្យល់នៅ រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ

### ៣.១ បទប្បញ្ញត្តិ

បទប្បញ្ញត្តិស្តីពីគុណភាពខ្យល់ជាចម្បងផ្អែកលើក្តីបារម្ភអំពីសុខភាពសាធារណៈ។ នៅទូទាំងពិភពលោកបទប្បញ្ញត្តិស្តីពីគុណភាពខ្យល់ប្រកាន់ខ្ជាប់តាមគោលការណ៍ណែនាំដែលកំណត់ដោយទីភ្នាក់ងារការពារបរិស្ថាន(EPAនៅសហរដ្ឋអាមេរិក ឬអង្គការសុខភាពពិភពលោក(WHO)។ ទោះជាយ៉ាងនេះក្តីការអនុលោមតាមបទប្បញ្ញត្តិទាំងនេះ អាចមានការលំបាកជាពិសេស សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ជាលទ្ធផលប្រទេសនីមួយៗ បង្កើតបទប្បញ្ញត្តិផ្ទាល់ខ្លួនដែលសម្របសម្រួលតាមកាលៈទេសៈ និងតម្រូវការជាក់លាក់របស់ប្រទេស។ នាពេលបច្ចុប្បន្ននេះមានឯកសារមួយចំនួនតូចប៉ុណ្ណោះពាក់ព័ន្ធនឹងគុណភាពខ្យល់ស្តង់ដារ។ខាងក្រោមនេះគឺជាសេចក្តីសង្ខេបអំពីឯកសារៈ

*តារាង ១. បទប្បញ្ញត្តិនៅកម្ពុជាពាក់ព័ន្ធនឹងការត្រួតពិនិត្យគុណភាពខ្យល់*

| ល.រ | ប្រភេទឯកសារ | ឆ្នាំ | បញ្ហាគុណភាពខ្យល់ |
|---|---|---|---|
| ១ | អនុក្រឹត្យលេខ ៤២ | ២០០០ | ការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេងដែលមានលក្ខណៈទូលំទូលាយពេកសម្រាប់ CO, NO2, SO2, O3, Pb, និង TSP |
| ២ | សារាចរណែនាំលេខ០១ | ២០២០ | វិធានការទប់ស្កាត់និងកាត់បន្ថយការបំពុលខ្យល់សាធារណៈដែលកំណត់គោលដៅលើឥន្ធនៈផូស៊ីល |
| ៣ | យុទ្ធសាស្ត្រខ្យល់ស្អាត | ២០២១ | ផែនការខ្យល់ស្អាតកម្ពុជា |
| ៤ | ប្រកាសលេខ ០៣៨ | ២០២០ | ការអនុវត្តសន្ទស្សន៍គុណភាពខ្យល់សម្រាប់ការត្រួតពិនិត្យគុណភាពខ្យល់នៅកម្ពុជា |
| ៥ | យុទ្ធសាស្ត្រចក្រា | ២០២៣ | យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ឆ្នាំ២០២៣-២០២៨ |

ផ្អែកលើឯកសារខាងលើនេះ មានតែអនុក្រឹត្យលេខ ៤២ (ដែលបានបង្កើតឡើងនៅឆ្នាំ ២០០០) ប៉ុណ្ណោះដែលបានលើកឡើងអំពីបទប្បញ្ញត្តិនៃកម្រិតបំពុលដែលអនុញ្ញាតនៅកម្ពុជា ដូចជា CO, NO2, SO2, O3, Pb, និង TSP។ ទោះជាយ៉ាងនេះក្តី បទប្បញ្ញត្តិនេះ មានលក្ខណៈទូលំទូលាយពេលហើយបទប្បញ្ញត្តិនេះ អាចថាសមស្របតាមបរិបទ កម្ពុជានៅពេលបង្កើតឡើង។ ក្នុងរយៈពេល ២០ ឆ្នាំចុងក្រោយនេះ កម្ពុជា បានឆ្លងកាត់ការផ្លាស់ប្តូរសំខាន់ៗគួរឱ្យកត់សម្គាល់ រួមទាំងការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធ អគារ និងការកើនឡើងនៃចំនួនយានយន្ត។ ដូច្នេះ ការកែសម្រួលលើបទប្បញ្ញត្តិនេះ គឺត្រូវការជាចាំបាច់។

បច្ចុប្បន្ននេះ សិនស័រតម្លៃទាប វាស់ស្ទង់តែភាគល្អិតនិចល PM2.5 និង PM10 ប៉ុណ្ណោះសម្រាប់គ្រប់ស្ថានីយទាំងអស់ ដោយសារតែរយៈពេលប្រហែល៥ឆ្នាំមកហើយ ចាប់ពីពេលដំឡើងមកដែលធ្វើឱ្យសិនស័រអេឡិចត្រូគីមី អស់សុពលភាព

និងមិនអាចវាស់ស្ទង់ការបញ្ចេញឧស្ម័នបាននោះឡើយ។ ទោះបីជាយើងវាស់ភាគល្អិតនិចល PM10 និង PM2.5 ក៏ដោយក៏បទប្បញ្ញត្តិបច្ចុប្បន្នដែលចូលជាធរមាន មិនបានចែងអំពីដែនកំណត់នោះដែរ។

ជាការចាំបាច់ផងដែរដែលត្រូវមានសិនស័រអេឡិចត្រូគីមីភ្ជាប់ទៅនឹងសិនស័រតម្លៃទាប ដោយសារតែចំនួនស្ថានីយបង្អែកមានកម្រិត។ ស្ថានីយបង្អែក គឺមិនមាននោះទេ នៅតាមបណ្ដាខេត្តមួយចំនួន ហេតុដូច្នេះ ទើបគុណភាពខ្យល់ គឺពឹងផ្អែកទាំងស្រុងទៅលើអំណានបានមកពីសិនស័រតម្លៃទាប។

តារាងខាងក្រោមនេះ បង្ហាញអំពីកម្រិតអនុញ្ញាតនៃគុណភាពខ្យល់។

*តារាង ២. ស្តង់ដារគុណភាពខ្យល់ជុំវិញថ្នាក់ជាតិ ធៀបទៅនឹងគោលការណ៍ណែនាំរបស់ អង្គការសុខភាពពិភពលោក*

| សារធាតុបំពុលខ្យល់ | រយៈពេលមធ្យម | អនុក្រឹត្យលេខ៤២[4] (mg/m3) | សុខភាពពិភពលោក[5] (µg/m3) |
|---|---|---|---|
| CO | ១-ម៉ោង | ៤០ | - |
| | ៨-ម៉ោង | ២០ | - |
| NO2 | ១-ម៉ោង | 0.៣ | - |
| | ២៤-ម៉ោង | 0.១ | ៥០ |
| | ១-ឆ្នាំ | - | ៣០ |
| SO2 | ១-ម៉ោង | 0.៥ | - |
| | ២៤-ម៉ោង | 0.៣ | ៥០ |
| | ១-ឆ្នាំ | 0.១ | - |
| O3 | ១-ម៉ោង | 0.២ | - |
| | ៨-ម៉ោង | - | ១២០ |
| Pb | ២៤-ម៉ោង | 0.00៥ | - |
| | ១-ឆ្នាំ | - | - |
| TSP | ២៤-ម៉ោង | 0.៣៣ | - |
| | ១-ឆ្នាំ | 0.១ | - |
| PM10 | ២៤-ម៉ោង | - | ១០០ |
| | ១-ឆ្នាំ | - | ៥០ |
| PM2.5 | ២៤-ម៉ោង | - | ៥០ |
| | ១-ឆ្នាំ | - | ២៥ |

4 អនុក្រឹត្យលេខ ៤២ ស្តីពីការបំពុលខ្យល់ និងការរំខានដោយសំឡេង ឆ្នាំ២០០០
5 គោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក ឆ្នាំ២០២១ @ គោលដៅបណ្ដោះអាសន្ន ២

## ៣.២ ការវាយតម្លៃសិនស័រតម្លៃទាប

ការវាយតម្លៃសិនស័រតម្លៃទាប គឺត្រូវបានអនុវត្តតាមរយៈការត្រួតពិនិត្យរូបសាស្ត្រ និងទិន្នន័យ។ ការត្រួតពិនិត្យរូបសាស្ត្ររួមមាន ការត្រួតពិនិត្យមើលភាពស្អាតរបស់សិនស័រ ដោយវាស់ស្ទង់អត្រាលំហូរ និងវាយតម្លៃភាពជាន់គ្នា នៃទិន្នន័យដែលសិនស័រនេះផ្តល់ជូន។ គួរឱ្យសោកស្តាយ នាឡិកាស្ទង់លំហូរ ឌីជីថលគឺមិនមានសម្រាប់ការសិក្សានេះទេ ដែលនាំឱ្យយើងដកចេញនូវការវាស់ស្ទង់អត្រាលំហូរ។ បន្ថែមពីនេះការត្រួតពិនិត្យទិន្នន័យ គឺត្រូវបានធ្វើឡើងដោយប្រៀបធៀបទិន្នន័យបានមកពីសិនស័រតម្លៃទាប ជាមួយនឹងទិន្នន័យបានមកពីស្ថានីយបង្អែក ដែលឧបករណ៍ទាំងពីរបាន ដំឡើងនៅរយៈចម្ងាយជិតគ្នា (ជាទូទៅតិចជាង ១០ ម៉ែត្រ) និងត្រូវបានវាស់ស្ទង់ស្របពេលជាមួយគ្នា។

ផ្អែកលើការត្រួតពិនិត្យរូបសាស្ត្រទាំងការប្រមូលទិន្នន័យនិង ម៉ូទ័របូមរបស់សិនស័រ គឺនៅដំណើរការល្អទាំងអស់។ ទោះបីជាមិនមាននាឡិកាស្ទង់លំហូរក្តី អត្រាលំហូរនៃសិនស័រ Oceanus គឺត្រូវបានកំណត់ជា ១.៣ L/min ± ០.១៥ ផ្អែកលើសៀវភៅណែនាំ។ ទោះជាយ៉ាងនេះក្តីអត្រាលំហូរសម្រាប់សិនស័រGRI-IAT គឺមិនបានបង្ហាញនោះទេ។ លើសពីនេះយើងបានសង្កេតឃើញថាសិនស័រនៅស្អាត និងផ្តល់ទិន្នន័យបានស្របគ្នាទៅនឹងម៉ាស៊ីនមេបានទាន់ពេលវេលា។

ដោយសារតែបច្ចុប្បន្ន នៅមិនទាន់មានឧបករណ៍ធ្វើព្យាសកម្ម ដំណើរការព្យាសកម្ម អាចធ្វើឡើងដោយការអនុវត្តការផ្ទៀងផ្ទាត់ជាមួយនឹងស្ថានីយបង្អែក។ ជាសំណាងល្អយើងមានស្ថានីយបង្អែកនៅគ្រប់ទីក្រុងគោលដៅទាំងអស់ រួមទាំងរាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តព្រះសីហនុ។ ដោយសារតែការត្រួតពិនិត្យនិងការធ្វើព្យាសកម្មជាប្រចាំខែ ពីសំណាក់ជំនាញការជនជាតិចិន យើងអាចសន្មតបានថា ស្ថានីយបង្អែក គឺធ្វើព្យាសកម្មបានត្រឹមត្រូវ និងដំណើរការបានយ៉ាងល្អ។ សិនស័រ ត្រូវបានដំឡើងនៅស្ថានីយបង្អែក (ឱ្យកាន់តែកៀកតាមដែលអាចធ្វើទៅបាន)។ បន្ទាប់មក ទិន្នន័យទាំងពីរសំណុំនេះ គឺត្រូវយកមកប្រៀបធៀប ដើម្បីកំណត់រកភាពលម្អៀងណាមួយ។ រូបភាពនៅទំព័របន្ទាប់នេះ គឺជាការប្រៀបធៀបទិន្នន័យរវាងសិនស័រតម្លៃទាប និងស្ថានីយបង្អែក។

*រូបភាព ៤. ការប្រៀបធៀបស្ថានីយបង្អែក និងសិនស័រនៅក្នុងខេត្តសៀមរាប ព្រះសីហនុ និងរាជធានីភ្នំពេញ*









ផ្អែកលើទិន្នន័យប្រៀបធៀប យើងបានធ្វើការប៉ាន់ស្មានជម្រាល និងចំណុចស្ទាក់។









សមីការ Eq.២ នឹងត្រូវបានអនុវត្តលើទិន្នន័យដែលទទួលបានពីសិនស័រ គឺហៅថាទិន្នន័យព្យាសកម្ម។ នីតិវិធីលម្អិតតាមជំហាន អាចរកបាននៅក្នុងឧបសម្ព័ន្ធ។

រូបភាព ៥ បង្ហាញពីកំហាប់មធ្យមក្នុងមួយម៉ោងនៃភាគល្អិតនិចល PM2.5 នៅខេត្តសៀមរាប ព្រះសីហនុ និងរាជធានីភ្នំពេញ។ ចំណុចមូលពណ៌ខៀវ តំណាងឱ្យទិន្នន័យដើមផ្តល់ដោយសិនស័រ ហើយចំណុចមូលពណ៌លឿង បង្ហាញពីកំហាប់កែសម្រួល បន្ទាប់ពីអនុវត្តសមីការ Eq.២ លើទិន្នន័យដើម។ ជាបន្តបន្ទាប់ កំហាប់កែសម្រួល គឺត្រូវបានរាយការណ៍ជាទិន្នន័យព្យាសកម្ម។ ជាការសំខាន់ណាស់ដែលត្រូវកត់សម្គាល់ថា ភាពលម្អៀងរវាងទិន្នន័យដើម និងទិន្នន័យកំណត់ គឺស្មើនឹងប្រហែលជា ៥-១០ μg/m³។ ទោះបីជាតម្លៃដាច់ខាត អាចនឹងមិនខ្ពស់ក៏ដោយ ក៏ភាគរយនៃការលម្អៀងគឺខ្ពស់ណាស់។ ជាទូទៅ តម្លៃដែលបានលៃតម្រូវ គឺត្រូវចាត់ទុកថាអាចទទួលយកបាននៅក្នុងចន្លោះ ±២០%។

*រូបភាព ៥. ការប្រៀបធៀបទិន្នន័យដើម និងទិន្នន័យបានធ្វើព្យាសកម្ម*









បន្ទាប់មក សិនស័រព្យាសកម្មអាចប្រើប្រាស់ដើម្បីដំឡើងនៅក្បែរសិនស័រតម្លៃទាបមួយទៀត សម្រាប់ការផ្ទៀងផ្ទាត់បន្តបន្ទាប់ក្នុងករណីដែលមិនមានស្ថានីយបង្អែកនៅក្នុងតំបន់។ តួលេខខាងក្រោមនេះ បង្ហាញអំពីការប្រៀបធៀបសិនស័រតម្លៃទាប និងសិនស័រតម្លៃទាប GRI-IAT ដែលបានធ្វើព្យាសកម្មជាមួយនឹងស្ថានីយបង្អែក ធៀបជាមួយនឹង Oceanus។

*រូបភាព ៦. ការប្រើប្រាស់សិនស័រដែលបានព្យាសកម្មរួច ដើម្បីធ្វើព្យាសកម្មសិនស័រមួយទៀត*









លក្ខណៈពិសេស និងលក្ខណៈបច្ចេកទេសសំខាន់ៗមួយចំនួននៃសិនស័រតម្លៃទាបដែលបានដំឡើង គឺបង្ហាញ នៅក្នុងតារាងខាងក្រោម។ ទោះជាយ៉ាងណាលក្ខណៈបច្ចេកទេសសំខាន់ៗមួយចំនួន មិនមាននៅក្នុងសៀវភៅណែនាំនោះទេ ឧទាហរណ៍ អត្រាលំហូរសំណាកគំរូ និងអាយុកាលនៃសិនស័រ។ អត្រាលំហូរសំណាកគំរូ គឺចាំបាច់នៅពេលធ្វើការវាស់ស្ទង់អត្រាលំហូរ ប៉ុន្តែមិនមែនសម្រាប់ការសិក្សានេះទេ។

*តារាង ៣. សង្ខេបអំពីលក្ខណៈចម្បងនៃសិនស័រតម្លៃទាបមានស្រាប់*

| ប៉ារ៉ាម៉ែត្រ | Oceanus[6] | GRI-IAT[7] | សម្គាល់ |
|---|---|---|---|
| ចន្លោះ PM2.5 | 0 - ១ 000 mg/m³ | 0 - ១ 000 mg/m³ | |
| ចន្លោះ PM10 | 0 - ១ 000 mg/m³ | 0 - ២ 000 mg/m³ | |
| គោលការណ៍ | របាយពន្លឺ | ឡាស៊ែរ | |
| អត្រាលំហូរ សំណាកគំរូ | ១.៣ L/នាទី ±0.១៥ | N/A | |
| ឧស្ម័ន | O3, NO2, SO2, CO, VOCs, $H_2S$ | CO, SO2, O3, NO2, សីតុណ្ហភាព, សំណើម | មិន ដំណើរការ |
| អាយុកាលសិនស័រ | គ្មាន | ២ ឆ្នាំ | |

## ៣.៣ ស្ថានភាពនៃស្ថានីយបង្អែក

ស្ថានីយបង្អែក ឆ្លងកាត់ការថែទាំ និងព្យាសកម្ម ជាទៀងទាត់ ដែលគាំទ្រដោយដៃគូសម្រាប់រយៈពេលពីរឆ្នាំ។ កំណត់ត្រាប្រចាំខែត្រូវបានកត់ត្រាយ៉ាងត្រឹមត្រូវក្នុងសៀវភៅបញ្ជីកំណត់ត្រាសម្រាប់ទុកជាឯកសារយោងនាពេលក្រោយ។កំណត់ត្រាទាំងនេះ ជាធនធានដ៏មានតម្លៃ ដែលអាចឱ្យយើងអង្កេត និងតាមដានសមត្ថភាពដំណើរការរបស់សិនស័រ តាមពេលវេលា។

*រូបភាព ៧. កំណត់ត្រាព្យាសកម្មរបស់ស្ថានីយបង្អែក*




6 សៀវភៅណែនាំប្រតិបត្តិការអំពីសិនស័រ Henanoceanus៖ AQM-09

7 សៀវភៅណែនាំអំពីផលិតផលនៃឧបករណ៍ Huana Guorui Instrument (GRI)៖ ការត្រួតពិនិត្យខ្យល់ GRI-IAT







វិសាលភាពកម្រិតលម្អៀង(Span drift) គឺជាការកើនឡើង ឬការថយចុះតាមសមាមាត្រ នៃការផ្លាស់ប្តូរតម្លៃដែលបានវាស់ធៀបនឹងតម្លៃដែលបានព្យាសកម្ម។ ផ្អែកលើទិន្នន័យដែលបានកត់ត្រា មានភស្តុតាងបញ្ជាក់ថា សិនស័រ បង្ហាញអំពីស្ថានភាពវិសាលភាពកម្រិតលម្អៀង (Span drift) ខ្ពស់ ជាទូទៅលើសពី ២០% គឺប្រឈមនឹងហានិភ័យនៃការឈប់ដំណើរការនៅពេលអនាគតដ៏ខ្លី។ ភាពលម្អៀងនៃ span drift ដូចដែលបានបង្ហាញនៅក្នុងរូបភាពខាងលើ បង្ហាញអំពីតម្លៃតិចជាង ២០% សម្រាប់ស្ថានីយនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា លើសពី ៣០% សម្រាប់ស្ថានីយសៀមរាប និងលើសពី ២០% សម្រាប់ស្ថានីយព្រះសីហនុ។ គួរឱ្យកត់សម្គាល់ ភាពលម្អៀងនេះ បញ្ជាក់ថាសិនស័រ SO2 នៅស្ថានីយសៀមរាប និងសិនស័រ CO និង NOx នៅស្ថានីយព្រះសីហនុ អាចស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ។ ជាភស្តុតាង ក្នុងអំឡុងពេលចុះត្រួតពិនិត្យទីតាំងផ្ទាល់ យើងបានបញ្ជាក់ថាសិនស័រ CO នៅស្ថានីយព្រះសីហនុ បច្ចុប្បន្ន គឺកំពុងជួសជុល។ ទោះបីជាយើងមិនអាចធានាបាននូវភាពច្បាស់លាស់អំពីការមិនដំណើរការដែលបានព្យាករណ៍ក៏ដោយ ក៏ការរៀបចំផែនការបុរេសកម្មសម្រាប់ការផ្លាស់ប្តូរគ្រឿងបន្លាស់ គឺចាត់ទុកថាអាចណែនាំឱ្យអនុវត្តបាន។

## ៣.៤ ចំណាយប្រតិបត្តិការសម្រាប់ស្ថានីយបង្អែក និងសិនស័រ

ស្ថានីយបង្អែក គឺជាស្ថានីយដ៏សំខាន់សម្រាប់កម្ពុជា។ ដោយសារតែការថែទាំ និងព្យាសកម្មជាទៀងទាត់ ទិន្នន័យដែលផ្តល់ជូនដោយស្ថានីយបង្អែក នឹងត្រូវយកធ្វើជាបន្ទាត់គោល ដែលសិនស័រតម្លៃទាបអាចយកតាម/សម្របតាម។ ទោះជាយ៉ាងនេះក្តី ថ្លៃចំណាយលើការថែទាំ និងព្យាសកម្ម គឺមានតម្លៃថ្លៃណាស់។ តារាងខាងក្រោមនេះ បង្ហាញអំពីការប្រើប្រាស់ចម្បងៗដែលចាំបាច់សម្រាប់ប្រតិបត្តិការស្ថានីយបង្អែក។ ចំណាយសរុប ចាំបាច់សម្រាប់ប្រតិបត្តិការ និងការថែទាំ៖

*តារាង ៤. ការប៉ាន់ស្មានចំណាយសម្រាប់ការប្រើប្រាស់ចម្បងៗនៃស្ថានីយបង្អែក*

| ល.រ | សម្ភារៈ | ឯកតា | បរិមាណ | តម្លៃក្នុងមួយឯកតា (USD) | ចំនួនទឹកប្រាក់ក្នុងមួយអាយុកាល (USD) | អាយុកាល (ឆ្នាំ) | ចំនួនទឹកប្រាក់ក្នុងមួយឆ្នាំ (USD) |
|---|---|---|---|---|---|---|---|
| ១ | តម្រងហ្វៃប៊ីរកញ្ចក់ PMIO/PM2.5 | ចំនួន | ១២០ | ១២០ | ១៤ ៤០០ | ១ | ១៤.៤០០ |
| ២ | PTFE សន្ទះតម្រង CO,03,S02,NO | ចំនួន | ៤០ | ៥០ | ២ ០០០ | ១ | ២.០០០ |
| ៣ | ស៊ីឡាំងឧស្ម័នស្តង់ដារ CO | ធុង | ១០ | ២៩៣០ | ២៩ ៣០០ | ២ | ១៤.៦៥០ |
| ៤ | ស៊ីឡាំងឧស្ម័នស្តង់ដារ NO | ធុង | ១០ | ២៩៣០ | ២៩ ៣០០ | ២ | ១៤ ៦៥០ |
| ៥ | ស៊ីឡាំងឧស្ម័នស្តង់ដារ S02 | ធុង | ១០ | ២៩៣០ | ២៩ ៣០០ | ២ | ១៤ ៦៥០ |
| ៦ | បន្ទះសិនស័រ AQM-200 Calibrator | ចំនួន | ១០ | ៦៦០ | ៦ ៦០០ | ២ | ៣ ៣០០ |
| ៧ | ប៊ូឡុង 1/4 316 តម្រងអ៊ីណុក | ចំនួន | ៣០ | ៣២ | ៩៦០ | ១ | ៩៦០ |
| សរុប | | | | | ១១១ ៨៦០ | | ៦៤ ៦១០ |

តារាងខាងលើ មិនរួមបញ្ចូលពន្ធនាំចូល និងការដឹកជញ្ជូនឡើយ។ ក្នុងន័យផ្នែកសុវត្ថិភាព ធុងឧស្ម័ន គួរតែវេចខ្ចប់ដាច់ដោយឡែក និងត្រូវដាក់នៅក្នុងលក្ខខណ្ឌដែលគ្រប់គ្រងបានល្អសម្រាប់ការដឹកជញ្ជូន ដែលអាចនឹងត្រូវចំណាយច្រើន។ បន្ថែមពីលើតារាងខាងលើ សម្ភារៈប្រើប្រាស់តូចតាច គ្រឿងបន្លាស់ អគ្គិសនី អ៊ីនធឺណិត ចំណាយប្រតិបត្តិការ ជាដើម គឺត្រូវការចាំបាច់។ ដូច្នេះ ដើម្បីធ្វើប្រតិបត្តិការស្ថានីយបង្អែកឱ្យបានពេញលេញ ចាំបាច់ត្រូវមានទុនបម្រុង ១០០ ០០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំក្នុងមួយស្ថានីយ។

នៅកម្ពុជា មានស្ថានីយបង្អែកសរុបចំនួន ១០ ដែលមាន ២ នៅភ្នំពេញ និង ៨ ស្ថានីយនៅតាមបណ្តាខេត្ត ខុសៗគ្នា។ ជាមួយនឹងថ្លៃចំណាយទាំងនេះ រួមទាំងថ្លៃចំណាយប៉ាន់ស្មានចំនួន ៦ ៩៦០ ដុល្លារអាមេរិកសម្រាប់ការធ្វើដំណើរចុះតាមខេត្តដើម្បីធ្វើការថែទាំ ថ្លៃចំណាយប្រតិបត្តិការ និងថែទាំសរុបសម្រាប់ស្ថានីយបង្អែកទាំង ១០ គឺប៉ាន់ស្មានថាមានស្មើនឹងប្រមាណជា ១ ០៥៥ ៦៨០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ។

ពាក់ព័ន្ធនឹងសិនស័រវិញ យើងមានសិនស័រសរុបចំនួន ៤០ គ្រឿងនៅ ២៤ ខេត្តក្រុងនៅទូទាំងប្រទេសកម្ពុជា។ ចំណាយប្រតិបត្តិការ និងថែទាំសរុបសម្រាប់សិនស័រ គឺត្រូវបានប៉ាន់ស្មានថាមានចំនួនស្មើនឹង ៣៩ ៨៤០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ ដោយ ៣០% នៃចំណាយនេះ គឺសម្រាប់គ្រឿងសម្ភាសៈដែលត្រូវការចាំបាច់សម្រាប់សិនស័រ និងចំណាយនៅសល់គឺសម្រាប់ថ្លៃធ្វើដំណើរសម្រាប់ជំនាញការពីរាជធានីភ្នំពេញ ធ្វើដំណើរទៅតាមខេត្តខុសៗគ្នាក្នុងមួយឆ្នាំ។

## ៣.៥ ការជ្រើសរើសឧបករណ៍សិនស័រតម្លៃទាប

ផ្អែកលើការសិក្សាមួយនៅឆ្នាំ២០១៩, Federico et al.[8] បានធ្វើការវាយតម្លៃលទ្ធផលដំណើរការនៃសិនស័រ តម្លៃទាបចំនួន ១១២ គ្រឿងសម្រាប់ការត្រួតពិនិត្យគុណភាពខ្យល់នៅអ៊ីតាលី។ ការសិក្សានេះបានធ្វើឡើងដោយការប្រៀបធៀបទិន្នន័យគុណវិស័យនៃសិនស័រតម្លៃទាបធៀបជាមួយនឹងការវាស់ស្ទង់នៅស្ថានីយបង្អែក។ការសិក្សានេះបានបញ្ចប់ដោយការចែករំលែកអំពីបញ្ជីសម្រាំងនៃសិនស័រដែលបង្ហាញអំពីដំណើរការល្អជាមួយនឹងការវាស់ស្ទង់នៅស្ថានីយបង្អែក។

*រូបភាព ៨. ទំនាក់ទំនងរវាង R2 និងជម្រាលសម្រាប់ការវាយតម្លៃលទ្ធផលដំណើរការនៃសិនស័រ*




ផ្ទៃខាងក្រោយពណ៌ខៀវ តំណាងឱ្យតំបន់ជ្រើសរើសល្អបំផុតសម្រាប់សិនស័រ។ សិនស័រល្អបំផុត គួរតែជាសិនស័រដែលឈានដល់ចំណុចនិយាមការ R2 = 1 និងជម្រាល = 1។ នៅក្នុងផ្ទៃខាងក្រោយពណ៌ខៀវ សិនស័រដែល បានជ្រើសរើស គឺត្រូវបានសង្ខេបជូននៅក្នុងតារាងខាងក្រោម៖

8 Karagulian, F., Barbiere, M., Kotsev, A., Spinelle, L., Gerboles, M., Lagler, F., Redon, N., Crunaire, S., & Borowiak, A. (2019). ការត្រួតពិនិត្យលទ្ធផលដំណើរការនៃសិនស័រតម្លៃទាបសម្រាប់ការត្រួតពិនិត្យគុណភាពខ្យល់។ បរិយាកាស 10(9), 506។

*តារាង ៥. សិនស័រតម្លៃទាបដែលណែនាំផ្អែកលើលទ្ធផលដំណើរការ*

| គំរូ | សារធាតុបំពុល | ប្រភេទ | ចំហ/បិទ | Living | តម្លៃ |
|---|---|---|---|---|---|
| 2B Tech. (POM) | O3 | UV | ប្រអប់ខ្មៅ | Y | ៤៥០០ |
| PA-II | PM1, PM2.5, PM10 | OPC | ប្រអប់ខ្មៅ | Y | ២០០ |
| AirSensEUR (v.1) | NO, NO2, O3 | អេឡិចត្រូគីមី | ប្រអប់ខ្មៅ | Y | ១៦០០ |
| PA-I | PM1, PM2.5, PM10 | OPC | ប្រអប់ខ្មៅ | N | ១៥០ |
| S-500 | NO2, O3 | MOs | ប្រអប់ខ្មៅ | Y | ៥០០ |
| SNAQ | NO2, CO, NO | អេឡិចត្រូគីមី | ប្រអប់ខ្មៅ | Y | - |
| Vaisala AQT410 v.1.15 | CO, NO2, | អេឡិចត្រូគីមី | ប្រអប់ខ្មៅ | Y | ៣៧០០ |
| MetOne (MN) | PM2.5 | OPC | ប្រអប់ខ្មៅ | Y | ១៩០០ |
| AirNut | PM2.5 | nephelometer | ប្រអប់ខ្មៅ | Y | ១៥០ |
| Egg v.2 (PM) | PM2.5, PM10 | nephelometer | ប្រអប់ខ្មៅ | Y | ២៨០ |
| AQY v0.5 | PM2.5, NO2, O3 | អេឡិចត្រូគីមី, MOs | ប្រអប់ខ្មៅ | បានធ្វើ | ៣០០០ |
| CairClip $O^3/NO^2$ | O3, NO2 | អេឡិចត្រូគីមី | ប្រអប់ខ្មៅ | Y | ៦០០ |
| AQMesh v3.0 | CO, NO | អេឡិចត្រូគីមី | ប្រអប់ខ្មៅ | N | ១០,០០០ |
| AQT410 v.1.11 | O3 | អេឡិចត្រូគីមី | ប្រអប់ខ្មៅ | Y | ៣៧០០ |
| AirVeraCity | CO, NO2, O3 | អេឡិចត្រូគីមី, MOs | ប្រអប់ខ្មៅ | Y | ១០,០០០ |

ក្នុងន័យសេដ្ឋកិច្ច ចំនួនស្ថានីយបង្អែក គួរតែមានកម្រិត និងចំនួនសិនស័រតម្លៃទាបគួរតែបង្កើនឱ្យបានច្រើន។ ស្ថានីយបង្អែក គឺត្រូវបានណែនាំឱ្យដំឡើងនៅក្នុងទីក្រុងធំៗដូចជា រាជធានីភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ។ ក្រៅពីនោះ ចំនួនសិនស័រតម្លៃទាប គួរតែបង្កើនឱ្យបានច្រើននៅទូទាំងប្រទេស។ សិនស័រតម្លៃទា បជួយសន្សំសំចៃទាំងថ្លៃដំឡើង ក៏ដូចជាថ្លៃចំណាយប្រតិបត្តិការ ហើយមានអាយុកាលប្រើប្រាស់យ៉ាងតិចពីរឆ្នាំ សម្រាប់ប្រភេទអេឡិចត្រូគីមី។ នៅពេលដែលប្រើប្រាស់សិនស័រតម្លៃទាប ចាំបាច់ត្រូវធ្វើព្យាសកម្ម ដើម្បីរក្សាគុណភាពទិន្នន័យ។

ការសិក្សានេះ ណែនាំឱ្យដំឡើងសិនស័របន្ថែមនៅក្នុងខេត្តសៀមរាប និងខេត្តព្រះសីហនុ ស្របតាមតារាង ៧។ តារាង ៦ ខាងក្រោម បង្ហាញអំពីចំនួនសិនស័រដែលបានណែនាំឱ្យដំឡើងនៅក្នុងខេត្តសៀមរាប ព្រះសីហនុ ក៏ដូចជានៅរាជធានីភ្នំពេញផងដែរនៅពេលខាងមុខ ដើម្បីគ្របដណ្ដប់លើតំបន់សំខាន់ៗនៃទីក្រុង អមជាមួយនឹងការប៉ាន់ស្មានអំពីថ្លៃចំណាយនៃសិនស័រ។

*តារាង ៦. ចំនួនសិនស័រដែលបានណែនាំនៅក្នុងក្រុងទាំងបី និងការចំណាយពាក់ព័ន្ធ*

| ទីតាំង | ចំនួនសិនស័រ | តម្លៃ/ឯកតា | សរុប [ដុល្លារអាមេរិក] * |
|---|---|---|---|
| ភ្នំពេញ | ៣ | ២៨៩ | ៨៦៧ |
| សៀមរាប | ៣ | ២៨៩ | ៨៦៧ |
| ព្រះសីហនុ | ២ | ២៨៩ | ៥៧៨ |
| សរុប | | | ២ ៣១២ |

សម្គាល់៖ តម្លៃគិតជាអឺរ៉ូ @2019, OPC៖ ឧបករណ៍រាប់ភាគល្អិតអុបទិក, MOs៖ សិនស័រលោហៈអុកស៊ីត

ប្រភេទសិនស័រដែលបានណែនាំឱ្យដំឡើងនៅក្នុងក្រុងទាំងបីមាន៖

ម៉ូឌែល៖ Purple Air, Flex Air Quality Monitor

ម៉ាក៖ Purple Air

ផលិតផលសហរដ្ឋអាមេរិក

វាស់៖ PM0.3, 0.5, 1, 2.5, 10

ប្រភេទ៖ OPC



## ៣.៦ ស្ថានភាពនៃសមត្ថភាពបច្ចេកទេសនៅកម្ពុជា

បុគ្គលិកបច្ចេកទេស បានបង្ហាញអំពីលទ្ធផលការងារល្អគួរសមចំពោះកិច្ចការប្រចាំថ្ងៃរួមទាំងការដំឡើងសិនស័រ ឡើងវិញ និងការសម្អាត។ បុគ្គលិកមួយចំនួន បានទទួលការបណ្តុះបណ្តាលលម្អិតពីជំនាញការជនជាតិចិន នៅក្នុងការថែទាំ និងព្យាសកម្មស្ថានីយបង្អែក។

លំហូរប្រតិបត្តិការ ពីការដំឡើងសិនស័រ ដល់ការទទួលទិន្នន័យ រួមមានជំហានមួយចំនួនដែលអាចមានកំហុសកើតឡើង ដូចជាម៉ាស៊ីនបូមមិនដំណើរការសិនស័រ ដំណើរការដោយមិនផលិត ទិន្នន័យ ទិន្នន័យទាបពេក ឬខ្ពស់ពេក បញ្ហាបញ្ជូនទិន្នន័យ បញ្ហាធូន់ធ្ងរជាដើម។ នៅក្នុងករណីភាគច្រើន មន្ត្រីបច្ចេកទេសបានបង្ហាញអំពីសមត្ថភាពនៅក្នុងការគ្រប់គ្រងស្ថានភាពទាំងនេះ។

ចំពោះការវិភាគទិន្នន័យវិញ មន្ត្រីមានបទពិសោធន៍ប្រើប្រាស់គំរូ Excel និងបានផ្លាស់ប្តូរពីការប្រើប្រាស់គំរូនៅលើម៉ាស៊ីនមេដែលមានប្រសិទ្ធភាព និងសន្សំសំចៃពេលវេលាបានច្រើន។ ទោះបីជាពួកគាត់អាចអាន និងយល់ទិន្នន័យបានមួយផ្នែកក៏ដោយ ក៏ការបណ្តុះបណ្តាលបន្ថែមស្តីពីការវាយតម្លៃទិន្នន័យ គឺមានសារៈសំខាន់ណាស់សម្រាប់ការវាយ តម្លៃទិន្នន័យមុនពេលដំណើរការ

*ថ្លៃសេវាបន្ថែមសម្រាប់ការដឹកជញ្ជូន និងការដំឡើងគឺមិនបានបញ្ចូលនៅក្នុងតារាងនេះទេ។

ដោយធ្វើការកែសម្រួលនៅពេលចាំបាច់។

បញ្ហាប្រឈមនានា ត្រូវបានកំណត់នៅក្នុងការវាយតម្លៃសមត្ថភាពបច្ចេកទេស។ ទីមួយ រចនាសម្ព័ន្ធប្រតិបត្តិការ រួមបញ្ចូលមន្ត្រីបច្ចេកទេសពីកម្រិតក្រសួងដែលទទួលបន្ទុកប្រតិបត្តិការសិនស័រ ឬស្ថានីយទាំងអស់នៅទូទាំងប្រទេស។ ទោះជាយ៉ាងនេះក្តី ចំនួនមន្ត្រីបច្ចេកទេសនៅកម្រិតក្រសួងនៅមានកម្រិតគួបផ្សំជាមួយនឹងទំនួលខុសត្រូវផ្សេងៗទៀតនាំឱ្យបង្កជាបញ្ហាប្រឈម។

ការថែទាំសិនស័រ ឬស្ថានីយ គឺត្រូវបានធ្វើឡើងក្រោយពេលដែលសិនស័រឈប់ដំណើរការ និងខ្វះក្របខណ្ឌត្រួតពិនិត្យ និងដោះស្រាយឱ្យបានត្រឹមត្រូវ។ ការអនុវត្តការថែទាំមិនស្របគ្នានេះ អាចមានភាពខុសគ្នាពីមន្ត្រីម្នាក់ទៅមន្ត្រីម្នាក់ទៀត។

បុគ្គលិកពីររូប ទទួលខុសត្រូវចំពោះការដំណើរការទិន្នន័យ ហើយពួកគាត់អាចជំនួសគ្នាទៅវិញទៅមកបាននៅពេលដែលមានបុគ្គលិកម្នាក់ជាប់រវល់។ ទោះជាយ៉ាងនេះក្តី លំហូរការងារនៃការដំណើរការទិន្នន័យ គួរតែរួមបញ្ចូលបុគ្គលដាច់ដោយឡែកសម្រាប់ការវិភាគ និងការត្រួតពិនិត្យ (ផ្ទៀងផ្ទាត់) ដើម្បីធានាបាននូវការត្រួតពិនិត្យគុណភាពមុនពេលដាក់ជូនដល់ថ្នាក់ដឹកនាំស្នើសុំការអនុម័ត។ ដោយសារតែខ្វះបុគ្គលិក ពួកគាត់ត្រូវសហការគ្នា និងផ្លាស់ប្តូរតួនាទីគ្នាទៅវិញទៅមក ប៉ុន្តែការបែងចែកតួនាទីច្បាស់លាស់ គឺចាំបាច់ណាស់ក្នុងការធានាឱ្យបាននូវជនបង្គោលដាច់ដោយឡែក។

## ៣.៧ ការវាយតម្លៃទីតាំងសិនស័រ

តាមបច្ចេកទេសទីតាំងដំឡើងសិនស័រគឺត្រូវបានកំណត់ដោយផ្អែកលើដង់ស៊ីតេប្រជាជន និងប្រភពបំពុល។ គុណភាពខ្យល់ជុំវិញ មានឥទ្ធិពលយ៉ាងខ្លាំងមកលើសុខភាពសាធារណៈដោយផ្ទាល់ និងមកលើកំណើនសេដ្ឋកិច្ចដោយប្រយោលដែលធ្វើឱ្យតំបន់ទីប្រជុំជនប្រមូលផ្តុំច្រើនបំផុតគឺល្អបំផុតសម្រាប់ស្ថានីយត្រួតពិនិត្យ។មិនទាន់មានការកំណត់អំពីបទប្បញ្ញត្តិឬទ្រឹស្តីដែលបញ្ជាក់អំពីកម្រិតកំណត់នៃចម្ងាយសម្រាប់ការដំឡើងសិនស័រនោះទេ ទោះបីជាមានការសិក្សាអំពីចំនួនប្រជាជនជៀបនឹងចម្ងាយពីស្ថានីយត្រួតពិនិត្យហើយក៏ដោយ។

ប្រទេសម៉ាឡេស៊ី បានធ្វើការសិក្សាបែបនេះរួចហើយដោយមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវស្តីពីថាមពល និងខ្យល់ស្អាត (Centre for Research on Energy and Clean Air – CREA ) ជាមួយនិង ស្ថាប័ន Greenpeace[9] ហើយជាលទ្ធផលបានបង្ហាញថា ប្រទេសម៉ាឡេស៊ី មានស្ថានីយតាមដានគុណភាពខ្យល់ដែលអាចដំណើរការបានយ៉ាងល្អសម្រាប់តំបន់ដែលមានប្រជាជនរស់នៅច្រើន ក្នុងរង្វង់ ៥០ Km ពីស្ថានីយ។ របាយការណ៍នោះក៏បានបង្ហាញដែរថា ចំនួនប្រជាជន ១៥% រស់នៅក្នុងរង្វង់ ៥Km ពីស្ថានីយ ហើយប្រជាជនប្រមាណ ២៤% រស់នៅក្នុងរង្វង់ពី ៥ ទៅ ១០ Km ពីស្ថានីយ ហើយចំនួនប្រជាជន ៥០% ទៀតរស់នៅក្នុងរង្វង់ពី ១០ ទៅ ៥០ Km ពីស្ថានីយ។ មានប្រជាជនប្រមាណតែ ១១% ប៉ុណ្ណោះ ដែលកំពុងរស់នៅឆ្ងាយពីស្ថានីយ ពោលគឺលើសពី ៥០Km ពីស្ថានីយ។

---

9 CREA. 2022. ការសិក្សាពីផលប៉ះពាល់នៃគុណភាពខ្យល់ លើសុខភាពសាធារណៈ និងសេដ្ឋកិច្ច ក្នុងប្រទេសម៉ាឡេស៊ី

*រូបភាព ៩. ផែនទីបង្ហាញទីតាំងស្ថានីយមានស្រាប់ និងទីតាំងសក្តានុពលថ្មីដែលសមស្របនៅខេត្តសៀមរាប និងខេត្តព្រះសីហនុ*



ការជ្រើសរើសទីតាំងនៅក្បែរប្រភពនៃការបំពុល ដូចជា រោងចក្រ រោងចក្រថាមពល ឬទីលានចាក់សំរាម គឺជាលក្ខណៈវិនិច្ឆ័យដ៏សំខាន់មួយ។ កម្រិតចម្ងាយនៅក្បែរទីតាំងទាំងនេះ ជួយឱ្យយើងយល់ដឹងកាន់តែច្បាស់ និងគ្រប់គ្រងកម្រិតនៃការបំពុលបាន។ ប្រសិនបើមានកំហាប់ខ្ពស់ចាំបាច់ត្រូវធ្វើសាវនកម្ម។

ទីតាំងដែលបានជ្រើសរើសដោយក្រសួងបរិស្ថាន ស្របគ្នាជាមួយនឹងគោលបំណង។ អនុសាសន៍ រួមបញ្ចូលការធ្វើបច្ចុប្បន្នភាពទីតាំងមានស្រាប់ ដោយផ្អែកលើការប្រែប្រួល និងការស្នើសុំទីតាំងថ្មី ប្រសិនបើមានឱកាសក្នុងការបង្កើនចំនួនស្ថានីយត្រួតពិនិត្យ។ រូបភាព១០បង្ហាញអំពីទីតាំងមានស្រាប់ និងទីតាំងដែលបានណែនាំនៅក្នុងខេត្តសៀមរាប និងខេត្តព្រះសីហនុ។

នៅខេត្តសៀមរាប ជាការណែនាំគឺត្រូវរក្សាទុកទីតាំង a និង b នៅលើផែនទី ស្របពេលដែលផ្លាស់ប្តូរទីតាំង c (ភូមិវប្បធម៌) ទៅទីតាំង 5 ប្រកចូលអង្គរវត្ត។ ភូមិវប្បធម៌មានសភាពស្ងាត់ និងមានម្លប់ច្រើន មិនសមស្របសម្រាប់ការប្រើសូឡានោះទេ ខណៈពេលដែលទីតាំងថ្មី ប្រកចូលអង្គរ មានភាពមមាញឹកនៅពេលថ្ងៃដោយមានភ្ញៀវមកទស្សនាប្រាសាទ។ ដោយពិចារណាទៅលើរបាយប្រជាជន ជាការណែនាំគឺអាចជ្រើសរើសទីតាំង ១ ឬទីតាំង ២ និងទីតាំង ៣ ឬទីតាំង ៤ សម្រាប់ស្ថានីយពីរផ្សេងទៀតនៅខេត្តសៀមរាប។

សម្រាប់ខេត្តព្រះសីហនុវិញ ទីតាំងទាំងបីដែលមានស្រាប់ គឺសមស្របសម្រាប់ការរក្សាទុកនៅដដែល។ លើសពីនេះប្រសិនបើអាចធ្វើទៅបាន ជាការណែនាំគឺត្រូវបន្ថែមស្ថានីយចំនួនពីរទៀត៖ ទីតាំង ១ នៅតំបន់ឧស្សាហកម្មនិងអាចជាទីតាំង ២, ៣ ឬ ៤ ដោយផ្អែកលើរបាយប្រជាជន។ ការដំឡើងស្ថានីយមួយនៅក្នុងតំបន់ឧស្សាហកម្ម នឹងផ្តល់នូវទស្សនៈដ៏មានតម្លៃអំពីបម្រែបម្រួលនៃការបំពុលខ្យល់នៅក្នុងតំបន់នោះ។

បន្ថែមពីលើគោលបំណងដែលបានកំណត់ការជ្រើសរើសទីតាំងមួយ ក៏ពឹងផ្អែកទៅលើហេដ្ឋារចនាសម្ព័ន្ធ និងការពិចារណាអំពីសុវត្ថិភាពផងដែរ។ ទីតាំងដែលបានជ្រើសរើស គឺចាំបាច់ត្រូវតែមិនមានឧបសគ្គដោយមានការផ្គត់ផ្គង់ថាមពលចាំបាច់និងទុកចិត្តបានដើម្បីប្រតិបត្តិការឧបករណ៍។ ក្តីបារម្ភអំពីសុវត្ថិភាពជាពិសេសនៅក្នុងបរិបទជាក់លាក់ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់អំពីភាពសមស្របរបស់ទីតាំងមួយ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងសម្របទីតាំង ឱ្យត្រូវជាមួយនឹងគោលបំណង ដែលបានបង្កើតឡើងក្តី ក៏នៅមានបញ្ហាប្រឈមកើតឡើងនៅក្នុងការកំណត់ទីតាំងដំឡើងសមស្រប ដែលជាញឹកញាប់គឺដោយសារតែបញ្ហាឯកជនភាព ដែលម្ចាស់ទីតាំងលើកឡើង។

សេចក្តីសង្ខេបអំពីទីតាំងនៅក្នុងខេត្តសៀមរាប និងខេត្តព្រះសីហនុ គឺមានបង្ហាញនៅក្នុងតារាងនាទំព័របន្ទាប់៖

*តារាង ៧. សង្ខេបអំពីទីតាំងមានស្រាប់ និងទីតាំងសក្តានុពលសម្រាប់ការត្រួតពិនិត្យគុណភាពខ្យល់*

| ខេត្ត | ទីតាំងលើផែនទី | | | និយាមការ | សម្គាល់ |
|---|---|---|---|---|---|
| សៀមរាប | មានស្រាប់ | a | មន្ទីររដ្ឋបាលនៃមន្ទីរខេត្តសៀមរាប | 13.372749896939256, 103.8956196594363 | ស្ថានីយបង្អែក |
| | | b | សួនព្រះរាជដំណាក់ | 13.362494386430457, 103.86008107865122 | សិនស័រ តម្លៃទាប |
| | | c | ភូមិវប្បធម៌កម្ពុជា | 13.376851978975266, 103.8317706837885 | សិនស័រ តម្លៃទាប |
| | ទីតាំងសក្តានុពល | 1 | សាកលវិទ្យាល័យអង្គរ | 13.350539690701853, 103.89241593413591 | មួយក្នុងចំណោមពីរ |
| | | 2 | សាលាបឋមសិក្សាតាប៉ិច | 13.34893212368018, 103.88233140820559 | |
| | | 3 | សង្កាត់ស្វាយដង្គំ | 13.364916045275725, 103.83527172776093 | មួយក្នុងចំណោមពីរ |
| | | 4 | សាលាបឋមសិ ក្សាគោកចក | 13.391826419985364, 103.84702030741819 | |
| | | 5 | ផ្លូវចូលអង្គរវត្ត | 13.410837970156344, 103.85706933451688 | |
| ព្រះសីហនុ | មានស្រាប់ | A | សាលាបឋមសិក្សាហ៊ុនសែនព្រះសីហនុ | 10.635894868596505, 103.50969927286302 | ស្ថានីយបង្អែក |
| | | B | សាលាស្រុកស្ទឹងហាវ | 10.735620773893839, 103.62694985371712 | សិនស័រ តម្លៃទាប |
| | | c | សាលាបឋមសិក្សាកំពេញថ្មី | 10.754013229240051, 103.61841059572775 | សិនស័រ តម្លៃទាប |
| | ទីតាំងសក្តានុពល | 1 | តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ | 10.628147798125505, 103.63713127599823 | |
| | | 2 | សាលាបឋមសិក្សា និងអនុវិទ្យាល័យឃ្លាំងលើ | 10.635096408712814, 103.54114114570726 | មួយក្នុងចំណោមបី |
| | | 3 | សាលាបឋមសិក្សាហ៊ុនសែនមិត្តភាព | 10.615233650052575, 103.54076783206004 | |
| | | 4 | មន្ទីរសុខាភិបាលខេត្តព្រះសីហនុ | 10.612781997170538, 103.52824804628774 | |

## ៤. អនុសាសន៍

ផ្អែកលើការសិក្សា យើងអាចផ្តល់ជូនអនុសាសន៍ដូចខាងក្រោម៖

**១.ក្របខណ្ឌបទប្បញ្ញត្តិជាតិគួរត្រូវបានបង្កើត។** អនុក្រឹត្យលេខ៤២ដែលមានស្រាប់គួរតែកែសម្រួលដើម្បីឱ្យត្រូវគ្នាទៅនឹងស្ថានភាពបច្ចុប្បន្ន។ បន្ថែមពីលើបទប្បញ្ញត្តិនេះ ចាំបាច់ត្រូវបង្កើតយុទ្ធសាស្ត្រមួយដើម្បីគាំទ្រដល់ការគ្រប់គ្រង និងប្រតិបត្តិការនៃស្ថានីយត្រួតពិនិត្យគុណភាពខ្យល់។ អមជាមួយនឹងយុទ្ធសាស្ត្រនេះចាំបាច់ត្រូវគូសបញ្ជាក់អំពីរបៀបវារៈសម្រាប់ការថែទាំស្ថានីយមានស្រាប់ និងការពង្រីក ស្ថានីយត្រួតពិនិត្យគុណភាព ខ្យល់ថ្មីៗ។

បច្ចុប្បន្ន ក្រសួងបរិស្ថានបានបញ្ចប់ពង្រៀងលើការធ្វើបច្ចុប្បន្នភាពអនុក្រឹត្យលេខ៤២ និងកំពុងពិនិត្យមើលក្របខណ្ឌច្បាប់ដោយក្រុមមេធាវី។ ក្រសួងសង្ឃឹមថា សេចក្តីពង្រៀងនេះ អាចនឹងបញ្ចប់និងចូលជាធរមានសម្រាប់ការប្រើប្រាស់ក្នុងឆ្នាំនេះ ដើម្បីពង្រឹងការគ្រប់គ្រងគុណភាពខ្យល់នៅកម្ពុជា។

**២. ការពង្រីកស្ថានីយត្រួតពិនិត្យគុណភាពខ្យល់ដើម្បីសម្របតាមកំណើនទីក្រុងគឺមានសារៈសំខាន់ណាស់។** ក្រុមការងារទទួលបន្ទុកថែទាំ និងព្យាសកម្ម ត្រូវតែរៀបចំឡើងវិញ ដោយមានការផ្ទេរអំណាចទៅកាន់មន្ទីរខេត្ត ឬក្រុង។ ជាការសំខាន់ណាស់ចាំបាច់ត្រូវកសាងសមត្ថភាពមន្ត្រីនៅតាមនាយកដ្ឋាន។ ការរៀបចំបែបនេះជួយគាំទ្រដល់ការអភិវឌ្ឍនាពេលអនាគតរបស់កម្ពុជាដែលបទប្បញ្ញត្តិអាចនឹងមានភាពខុសគ្នាតាមទីក្រុង។ មន្ត្រីក្រសួងបរិស្ថាន នៅតែសំខាន់សម្រាប់ការគាំទ្រ និងការគ្រប់គ្រងទាំងមូល។ ក្នុងពេលបច្ចុប្បន្ននេះគេឃើញថារាជរដ្ឋាភិបាលនៅមិនទាន់មានគម្រោងផ្ទេរសិទ្ធិ និងភារកិច្ចនៃការគ្រប់ស្ថានីយទៅអោយមន្ទីរខេត្តនៅឡើយ។ តាមការពិភាក្សាក្នុងកំឡុងពេលសិក្ខាសាលា មន្ទីរខេត្ត បានបង្ហាញចំណាប់អារម្មណ៍ក្នុងការទទួលយកសិទ្ធិនិងភារកិច្ចនេះ ជាមួយការគាំទ្រទាំងផ្នែកបច្ចេកទេសនិងថវិការ។ វិធីសាស្ត្រនៃការគ្រប់គ្រងតាមបែបសហការគ្នានេះ គឺមានប្រសិទ្ធិភាពខ្ពស់ពិសេសលើនៃសេដ្ឋកិច្ច។

**៣. ការធានាឱ្យបានថាស្ថានីយបង្អែក គឺស្ថិតក្នុងលក្ខខណ្ឌល្អទាមទារឱ្យមានយុទ្ធសាស្ត្រថែទាំនិងព្យាសកម្មបានល្អ ប្រសើរដោយមានការគាំទ្ររឹងមាំពីថ្នាក់គ្រប់គ្រងជាន់ខ្ពស់។** ការរៀបចំផែនការថវិកា ដូចបានពិភាក្សានៅក្នុងផ្នែក ៣.៤ គួរតែដឹកនាំដល់ដំណើរការនេះ។ ក្នុងករណី កង្វះថវិកា ជាការសំខាន់ណាស់ដែលត្រូវកំណត់ អាទិភាពការថែទាំសម្រាប់ស្ថានីយបង្អែកជាច្រើន។ ការពឹងផ្អែកទាំងស្រុងតែទៅលើសិនស័រតម្លៃទាបនៅទូទាំងប្រទេស គឺមិនអាចអនុវត្តទៅបានយូរអង្វែងនោះទេ។ ក្រសួងបរិស្ថានត្រូវតែមានទំនួលខុសត្រូវសម្រាប់ធានាអោយបាននូវថវិកាសម្រាប់ថែទាំស្ថានីយបង្អែកអោយមានដំណើរការល្អ។ ថវិកាចំបងសម្រាប់គោលបំណងនេះគួរតែជាថវិកាជាតិដែលកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ផែនការយុទ្ធសាស្ត្រថវិកាមានភាពសំខាន់ណាស់ដើម្បីធានានិរន្តរភាពនៃការគ្រប់គ្រងស្ថានីយដើម្បីទទួលបានទិន្នន័យដែលអាចទុកចិត្តបាន។

**៤. ឧបករណ៍សិនស័រចាប់សារធាតុបំពុលខ្យល់ដែលមានតម្លៃសមរម្យ គួរត្រូវបានបំពាក់នៅទូទាំងប្រទេស។** ការប្រើប្រាស់សិនស័រតម្លៃទាប គឺសមស្របបំផុតសម្រាប់បរិបទនៃប្រទេសកម្ពុជាដែលផ្តល់នូវការគ្របដណ្តប់យ៉ាងទូលំទូលាយពីស្ថានីយត្រួតពិនិត្យ ដោយចំណាយលើសេវាដំឡើង និងថែទាំទាប។ ទោះបីជាមានសិនស័រ តម្លៃទាបច្រើនក៏ដោយ ចំណុចទី ៣.៥ ផ្តល់នូវអនុសាសន៍អំពីជម្រើសទុកចិត្តបំផុត និងថ្លៃចំណាយពាក់ព័ន្ធ។

ក្រសួងបរិស្ថាន មិនទាន់មានគម្រោងពង្រីកស្ថានីយសិនស័រតម្លៃទាបនៅឡើយដោយសារបញ្ហាថវិកា។ ទោះបីជាយ៉ាងនេះក្តី នាយកដ្ឋាន គ្រប់គ្រងគុណភាពខ្យល់ សំលេង និងរំញ័រ បានបញ្ជាក់ថា ក្រសួងនឹងទទួលបានស្ថានីយបង្អែកចំនួនបីបន្ថែមទៀតក្នុងឆ្នាំ ២០២៤ នេះ។ ស្ថានីយទាំងនោះនឹងដាក់នៅ រាជធានីភ្នំពេញ សៀមរាប និង បាត់ដំបង ជាជំនួយពីសាធារណរដ្ឋកូរ៉េ។ ផែនការនេះ បានបង្ហាញពីជំហានជាយុទ្ធសាស្ត្រ ក្នុងការពង្រឹងសមត្ថភាពក្នុងផ្នែកសំខាន់ៗ ដែលស្របទៅនិងទិសដៅនៃការបង្កើនការគ្រប់គ្រងបរិស្ថាន និងសុខភាពសាធារណៈ។

**៥. ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់ គួរតែត្រូវបានពង្រីកស្របទៅតាមកំណើនរបស់ទីក្រុង ហើយរចនាសម្ព័ន្ធគ្រប់គ្រងបណ្ដាញត្រួតពិនិត្យគុណភាពខ្យល់ ចាំបាច់ត្រូវតែធ្វើវិមជ្ឈការទៅឱ្យមន្ទីរខេត្ត ដោយមានការគាំទ្រដល់ការកសាង សមត្ថភាព។**
មន្ទីរខេត្តនីមួយៗនៃក្រសួងបរិស្ថាន គួរតែទទួលខុសត្រូវចំពោះ ការតាមដានត្រួតពិនិត្យលើស្ថានីយត្រួតពិនិត្យនៅក្នុងខេត្តរបស់ខ្លួន។ តួនាទីរបស់ក្រសួង គឺត្រូវធានាធ្វើយ៉ាងណាឱ្យខេត្តទាំងអស់ប្រកាន់ខ្ជាប់តាមនីតិវិធី និងពិធីការដូចគ្នាដោយផ្តល់នូវការកសាងសមត្ថភាពសម្រាប់មន្ត្រីនៅថ្នាក់ខេត្ត។ វិធីសាស្ត្រនេះគឺមានប្រសិទ្ធភាពថ្លៃចំណាយ និងសន្សំសំចៃពេលវេលាបានច្រើនដោយលើកកម្ពស់ការគ្រប់គ្រង និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពនៃការត្រួតពិនិត្យគុណភាពខ្យល់ស្ថានីយត្រួតពិនិត្យគុណភាពខ្យល់នៅតាមបណ្តាខេត្តខុសៗគ្នា។

ដើម្បីឆ្ពោះទៅមុខ ជាការសំខាន់ណាស់ដែលកម្ពុជា ត្រូវតែថែទាំស្ថានីយបង្អែកមួយចំនួនឱ្យស្ថិតក្នុងស្ថានភាពល្អ ស្របពេលដែលពង្រីកសិនស័រតម្លៃទាបឱ្យគ្របដណ្តប់នៅតាមតំបន់ដែលនៅសល់។ ទិន្នន័យគុណភាពខ្យល់ដែលរក្សា និងព្យាសកម្មបានល្អនៅកម្ពុជា គឺអាចទុកចិត្តបាន ដែលគាំទ្រដោយភស្តុតាងវិទ្យាសាស្ត្រ។



# SITUATION ASSESSMENT REPORT AIR QUALITY MONITORING IN CAMBODIA

Copyright © 2024

Global Green Growth Institute

Jeongdong Building 19F 21-15 Jeongdong-gil

Jung-gu, Seoul 04518

Republic of Korea

The Global Green Growth Institute does not: (i) make any warranty, either express or implied; or (ii) assume any legal liability or responsibility for the accuracy, completeness, or any third party's use or the results of such use of any information contained herein; (iii) intend this template/guide as legal advice or as a substitute for legal advice or (iii) represent that its use by any third party would not infringe privately owned rights. The views and opinions of the authors expressed herein do not necessarily state or reflect those of the Global Green Growth Institute.

# TABLE OF CONTENTS

*ABBREVIATIONS* V

**1. BACKGROUND** 1

1.1 Introduction 1

1.2 Purpose 1

1.3 Scope and limitation of the study 2

1.4 Structure of the report 2

**2. DATA COLLECTION** 3

2.1 Air quality monitoring station 3

2.2 Maintenance and Calibration procedures 6

2.3 Target investigated location 7

2.4 Data management 7

2.5 Technical Capacity 8

**3. ASSESSMENT OF AIR QUALITY MONITORING STATIONS IN PHNOM PENH, SIEM REAP AND SIHANOUKVILLE** 9

3.1 Regulation 9

3.2 Assessment of low-cost sensors 10

